01711793

F76.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 09 / 2022
ម៉ោង (Time/Heure): 11:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Phillip RAPOZA** |
| | **ចៅក្រម យ៉ា ណារិន** |
| **ក្រឡាបញ្ជី៖** | **Peace MALLENI, ស៊ា ម៉ៅ, ផន ធឿន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០២២** |
| **ភាសា៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ:** |

---

# សេចក្ដីសង្ខេបនៃសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២

---

**សហព្រះរាជអាជ្ញា**
**ជា លាង**

**ជនជាប់ចោទ**
**ខៀវ សំផន**

Fergal GAYNOR (បម្រុង)

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Falguni DEBNATH

**<u>សហមេធាវីការពារក្តី ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

1. ដំណើរការនីតិវិធី

2. តុលាការចាប់ផ្ដើម៖ ម៉ោង ០៩ និង ៣០ នាទី ព្រឹក

3. **ប្រធាន៖** ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បន្តប្រកាសសាលដីកាស្ដាពរលើបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និងសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២។ សូមក្រឡាបញ្ជីរាយការណ៍ពីវត្តមានរបស់ភាគី និងមេធាវី។

4. ក្រឡាបញ្ជី៖ រាយការណ៍វត្តមានរបស់ភាគី និងមេធាវី

5. ប្រធាន៖ រឿងក្ដីបច្ចុប្បន្ន ហៅថា"សំណុំរឿង ០០២/០២" ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ព្រៃផ្សៃបំផុតមួយចំនួនដែលបានកើតឡើងក្នុងចំណោមមហាសោកនាដកម្ម និងមហន្តរាយក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានស្គាល់ថា ជាខ្មែរក្រហម បានគ្រប់គ្រងប្រទេសកម្ពុជា ដែលក្រោយមកត្រូវបានប្ដូរទៅជាកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពីដណ្ដើមបានអំណាច បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តបដិវត្តសង្គមនិយមទូទាំងប្រទេសតាមរយ:ទ្រឹស្ដី"មហាលោតផ្លោះមហាអស្ចារ្យ" ក្នុងគោលបំណងកសាងប្រទេស ការពារពីខ្មាំងសត្រូវ និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមកម្មករកសិករខ្មែរមួយដូចៗគ្នា និងគ្មានការប្រតិបត្តិសាសនា។ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិលត្រូវបានដកសិទ្ធិសេរីភាពជាមូលដ្ឋាន និងដាក់ឱ្យស្ថិតក្រោមអំពើឃោរឃៅហួសប្រមាណដែលរីករាលដាល។ វប្បធម៌ភ័យខ្លាចមានអត្ថិភាពគ្រប់ទីកន្លែងតាមរយៈការសម្លាប់ទ្រង់ទ្រាយធំ ការធ្វើទារុណកម្ម អំពើហិង្សា ការធ្វើទុក្ខបុកម្នេញ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើការដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត។ ក្រោមការគ្រប់របស់បក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតក្នុងចំណោមរបបឃោរឃៅហួសហេតុជាងគេបំផុតក្នុងសតវត្សទីម្ភៃ បានបណ្ដាលឱ្យមានការបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណពី ១,៥ ទៅ ២ លាននាក់។

6. រឿងក្ដីនេះមានទំហំធំធេង និងស្មុគស្មាញ។ ការបំបែកដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ តម្រូវឱ្យមានការជំនុំជម្រះពីរបន្តបន្ទាប់គ្នាលើបទចោទដាច់ដោយឡែកពីគ្នាសម្រាប់ជនជាប់ចោទបួននាក់ដូចគ្នា ដែលវិធានការនេះធ្វើឡើងសម្រាប់គោលបំណងនៃការគ្រប់គ្រងការជំនុំជម្រះ ព្រមទាំងបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទ។ ជនជាប់ចោទបីនាក់ក្នុងចំណោមបួននាក់ដែលត្រូវបានចោទ

ប្រកាន់កន្លងមកបានទទួលមរណភាព។ ឯកសារភាគច្រើនក្នុងសំណុំរឿងត្រូវបានបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ក.ត.។ ក្រៅពីការប្រឈមជាច្រើននេះ ពិភពលោកបានជួបប្រទះបញ្ហាជំងឺឆ្លង COVID-19 ដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងលក្ខណៈបទបែន និងផ្នែប្រឹតពីសំណាក់បុគ្គលិកនីមួយៗនៃស្ថាប័នតុលាការក្នុងការបន្តនីតិវិធីរឿងក្តីនេះ ឱ្យដំណើរការទៅមុខដោយគ្មានការអាក់ខានក្នុងការចេញសាលដីកានេះ។

7. អាស្រ័យហេតុនេះ បញ្ហាផ្នែកនីតិវិធី ផ្នែកអង្គហេតុ និងអង្គច្បាប់ដែលអាចប្តឹងសាទុក្ខបាន ត្រូវបានពិចារណាត្រឹមត្រូវ និងសម្រេចដោយចៅក្រមទាំងអស់នៃអង្គជំនុំជម្រះតុលាការកំពូល។ បន្ថែមលើនេះ ដោយពិចារណាលើបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ក្នុងការធានាថា សាលដីកាត្រូវប្រកាសឱ្យបានឆាប់រហ័ស។

8. សាលដីកាក្នុងរឿងក្តីនេះ ជាប់ពាក់ព័ន្ធទៅនឹង ខៀវ សំផន ដែលត្រូវបានរកឃើញថាបានទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់តួនាទីរបស់គាត់ ពាក់ព័ន្ធទៅនឹងខ្មែរក្រហមក្រោយពីការជំនុំជម្រះរយៈពេលយ៉ាងយូរ។ សាលដីកានេះមានកម្រាស់រាប់រយទំព័រ។ សូមប្រកាសសេចក្តីសង្ខេបដែលគូសបញ្ជាក់តែការយល់ឃើញសំខាន់ៗ និងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងផ្នែកសម្រេចសេចក្តីនៃរឿងក្តីនេះប៉ុណ្ណោះ។ សាលដីកាពេញលេញនឹងមានតាមក្រោយក្នុងពេលឆាប់ៗបន្ទាប់ពីដំណើរការនៃការកែសម្រួលនិងការបកប្រែត្រូវបានបញ្ចប់។ មានតែសាលដីកាជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញប៉ុណ្ណោះដែលមានអានុភាពចងកាតព្វកិច្ចផ្លូវច្បាប់។

9. ខៀវ សំផន បានកើតនៅក្នុងខេត្តស្វាយរៀងក្នុងឆ្នាំ ១៩៣១ និងមានអាជីពជាអ្នកនយោបាយល្បីល្បាញដ៏យូរលង់ក្នុងកម្ពុជា។ គាត់បានក្លាយជាសមាជិកនៃក្រុមអ្នកឆ្វេងនិយមបញ្ញវន្តខ្មែរដែលសិក្សានៅទីក្រុងប៉ារីសក្នុងទសវត្សរ៍ ១៩៥០ ខណៈពេលដែលគាត់កំពុងបន្តការសិក្សានៅសាកលវិទ្យាល័យថ្នាក់បណ្ឌិតក្នុងប្រទេសបារាំង។ នៅចុងក្រោយ គាត់បានលេចធ្លោយ៉ាងឆាប់រហ័សក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ កាន់កាប់តួនាទីជាន់ខ្ពស់នានាក្នុងបក្សកុម្មុយនីស្តកម្ពុជា រួមទាំងជាប្រធានគណៈប្រធានរដ្ឋ និងជាប្រមុខរដ្ឋ។

10. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. បានចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០២ ជាសេចក្តីសង្ខេប និងបានជូនដំណឹងដល់ភាគីនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ដោយបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត អំពើសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការ

ធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាពផងដែរពីបទប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកក្រុមជនជាតិវៀតណាម និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចជាអំពើមនុស្សឃាតគិតទុកជាមុន ការធ្វើទារុណកម្ម ការធ្វើបាបដែលបង្កដោយចេតនានូវព្យសនកម្ម ឬការឈឺចាប់ធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព និងការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់ជនស៊ីវិល។

11. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បើទោះបីជា ខៀវ សំផន ពុំបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដោយផ្ទាល់ក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះដោយសារជាផ្នែកនៃសហឧក្រិដ្ឋរួម និងតាមរយៈការជួយទំនុកបម្រុង។ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ខៀវ សំផន ជាប់ពន្ធនាគារអស់មួយជីវិត រួមបញ្ចូលគ្នាជាមួយទោសមួយជីវិតដែលបានដាក់នៅក្នុងសំណុំរឿង ០០២/០១ និងបានបង្គាប់ថា ជនជាប់ចោទត្រូវទទួលទោសទាំងនេះត្រួតគ្នាតែមួយ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកផ្នែកខ្លះនៃសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំសំណងផ្លូវចិត្ត និងសមូហភាព ព្រមទាំងបានយល់ព្រមទៅលើការសាងសង់ស្តូបរម្លឹកការចងចាំតាមឃុំជាក់លាក់ចំនួន ១៣ គម្រោង។

12. ខៀវ សំផន និងសហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខ និងសារណាតបរៀងៗខ្លួន ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សារណាជាលាយលក្ខណ៍អក្សរជំនួសឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

13. នៅបណ្តឹងសាទុក្ខ ខៀវ សំផន បានលើកឡើងថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងមានកំហុសប្រមាណជា ១.៨២៤ និងបានជំទាស់ទៅនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងទាំងមូល។ ចំណោះបញ្ហានេះ គាត់បានចោទប្រកាន់កំហុសក្នុងការចេញ និងការប្រកាសសាលក្រមដោយអង្គជំនុំជម្រះសាលាដំបូងដំបូងនិងបានចោទប្រកាន់កំហុសផងដែរពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី វិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ បទឧក្រិដ្ឋមូលដ្ឋាន និងបញ្ហានៃការទទួលខុសព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។ គាត់បានអះអាងថា កំហុសនោះតម្រូវឱ្យបដិសេធការដាក់ពិរុទ្ធភាព និងទោសដែលបានប្រកាសលើគាត់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ខៀវ សំផន ពុំបាន

ជំទាស់ដោយជាក់លាក់ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងបទចោទអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។ ទោះបីជានៅក្នុងបណ្ដឹងសារទុក្ខរបស់គាត់បានលើកយកបញ្ហាជាច្រើនដោយបានចោទប្រកាន់ថា កំហុសទាក់ទងនឹងសុច្ចរិតភាពទូទៅនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក៏ត្រូវសំដៅផងដែរចំពោះការពិចារណារបស់អង្គជំនុំជម្រះទាក់ទងនឹងបទចោទនេះក៏ដោយ ក៏បណ្ដឹងសាទុ្ខរបស់គាត់ដែលពាក់ព័ន្ធទៅនឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានកម្រិតត្រឹមកំហុសដែលរងការចោទប្រកាន់ទាំងនោះតែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍តែមួយគត់នៃបណ្ដឹងសាទុក្ខដោយបានជំទាស់ទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងករណីដែលជនរងគ្រោះជាបុរស។

14. អង្គជំនុំជម្រះតុលាការកំពូលបានស្ដាប់សវនាការផ្ទាល់មាត់របស់ភាគីលើបណ្ដឹងសាទុក្ខនៅថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ២០២១។ បន្ទាប់មក អង្គជំនុំជម្រះបានថយទៅធ្វើការពិភាក្សាសម្រេច ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះចេញសាលដីការបស់ខ្លួនលើបណ្ដឹងសាទុក្ខទាំងពីរ ដែលនឹងប្រកាសរួមជាមួយគ្នាដោយសារត្រូវបានបញ្ចប់ពេញលេញក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។ ដោយសារការជំទាស់នៃបណ្ដឹងសាទុក្ខមានចំនួនច្រើនដែលបានលើកឡើងដោយ ខៀវ សំផន នៅក្នុងសវនាការនេះ សូមប្រកាសតែសេចក្ដីសង្ខេបនៃការយល់ឃើញ និងការសម្រេចទាក់ទងទៅនឹងការជំទាស់ទាំងនេះដែលមានលក្ខណៈចម្រូងចម្រាស់ជាពិសេសប៉ុណ្ណោះ។ ការយល់ឃើញ និងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងទៅនឹងបណ្ដឹងសាទុក្ខទាំងពីរនេះ ត្រូវបានបង្ហាញនៅក្នុងសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរ ដែលនឹងជូនដំណឹងក្នុងពេលសមស្រប។ ខ្ញុំសូមបញ្ជាក់សាជាថ្មីថា មានតែសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរប៉ុណ្ណោះដែលមានអានុភាពផ្លូវច្បាប់។

15. ការសង្ខេបនៃការជំទាស់របស់ ខៀវ សំផន លើបណ្ដឹងសាទុក្ខនឹងត្រូវដោះស្រាយតាមលំដាប់លំដោយខាងក្រោម។

## ការចោទប្រកាន់កំហុសទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី

16. ជាបញ្ហាបឋម ខៀវ សំផន បានជំទាស់ថា តាមរយៈការខកខានក្នុងការចេញសាលក្រមជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញនៅថ្ងៃដែលសេចក្ដីសម្រេចសង្ខេបសាលក្រមត្រូវបានប្រកាស អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ធ្ងន់ធ្ងរដែលធ្វើឱ្យការប្រកាសសាលក្រមនោះគ្មានសុពលភាព និងមិនគោរពតាមវិធានបញ្ញត្តិ។ បន្ថែមលើនេះ គាត់បានអះអាងថា ចៅក្រមនៃអង្គជំនុំ

ជម្រះសាលាដំបូងបានអនុវត្តហួសវិសាលភាពនៃការជំនុំជម្រះរបស់ខ្លួននៅពេលដែលសាលក្រមមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹង និងថា អាស្រ័យហេតុនេះ ផ្នែកដទៃទៀតនៃបណ្តឹងសាទុក្ខរបស់គាត់ត្រូវចាត់ទុកជាអសារបង់ ពីព្រោះពិរុទ្ធភាព ឬភាពគ្មានទោសរបស់គាត់ពុំត្រូវបានជំនុំជម្រះត្រឹមត្រូវតាមច្បាប់។

17. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ខៀវ សំផន បានដឹងច្បាស់លាស់ពីចេតនារបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមសង្ខេបដែលសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរនឹងត្រូវជូនដំណឹងតាមក្រោយ។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងជាសាធារណៈអំពីចេតនារបស់ខ្លួន និងបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគី ជាពិសេសជនជាប់ចោទក្នុងការលើកការជំទាស់ណាមួយ ប៉ុន្តែពុំមានការលើកនោះឡើយ។ វិធាន ១០២(១) នៃវិធានផ្ទៃក្នុងចែងថា សាលក្រមត្រូវតែចេញ និងប្រកាសក្នុងសវនាការសាធារណៈមួយ និងថា សេចក្តីសង្ខេបនៃការយល់ឃើញ និងផ្នែកសម្រេចសេចក្តីត្រូវតែអានខ្លាំងដោយប្រធាន ឬចៅក្រមនៃអង្គជំនុំជម្រះនោះ។ វិធានដូចគ្នានេះបានចែងផងដែរថា ក្រឡាបញ្ជីត្រូវផ្តល់ច្បាប់ចម្លងនៃសាលក្រមដល់ភាគី និងធានាថា សាលក្រមត្រូវបានផ្សព្វផ្សាយដោយការិយាល័យរដ្ឋបាលតាមមធ្យោបាយសមស្រប។ ទោះជាយ៉ាងណាក្តីពុំមានការចែងជាក់លាក់ថា ការផ្តល់ ឬការផ្សព្វផ្សាយសាលក្រមត្រូវតែធ្វើឡើងក្នុងថ្ងៃតែមួយនៃសវនាការជាសាធារណៈនោះឡើយ។ ជាក់ស្តែង នេះជាការអនុវត្តន៍ធម្មតាក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិដែលមានទំហំបែបនេះដែលត្រូវចេញសាលក្រមសង្ខេបផ្ទាល់មាត់ជាមុនដោយអនុញ្ញាតឱ្យការបញ្ចប់នូវការកែសម្រួល និង/ឬដំណើរការនៃការបកប្រែពេញលេញ។

18. សាលក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវបានចេញ និងប្រកាសស្របតាមច្បាប់នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ជាទម្រង់សេចក្តីសង្ខេប បើទោះបីជាសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរត្រូវបានជូនដំណឹង និងផ្សព្វផ្សាយនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩។ សិទ្ធិរបស់ ខៀវ សំផន ក្នុងការពិនិត្យលើសេចក្តីសម្រេចដែលជាមូលដ្ឋាននៃការដាក់ពិរុទ្ធភាព និងការដាក់ទោសលើរូបគាត់ នៅតែមានសុពលភាពទាំងស្រុងក្រោយពេលការជូនដំណឹង និងការផ្សព្វផ្សាយសាលក្រម ដូចបានបង្ហាញតាមរយៈការជំនុំជម្រះបច្ចុប្បន្នលើបណ្តឹងសាទុក្ខរបស់គាត់ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងនេះ។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ទាក់ទងនឹងបញ្ហានេះត្រូវបដិសេធចោល។

19. ខៀវ សំផន បានលើកឡើងបន្ថែមថា ពេញមួយអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ "សិទ្ធិជាមូលដ្ឋានរបស់គាត់ដែលត្រូវបានទទួលស្គាល់ដោយក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ពុំត្រូវបានគោរពដោយសារលទ្ធផលនៃវិធីសាស្ត្រលម្អៀងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការ

អនុវត្តគោលការណ៍ណែនាំនៃកិច្ចដំណើរការនីតិវិធី និងវិធានស្តីពីភស្តុតាង"។ ខៀវ សំផន អះអាងថា វិធីសាស្ត្រដែលមានកំហុសជាមូលដ្ឋានបាននាំឱ្យអង្គជំនុំជម្រះសាលាដំបូងរំលោភបំពានដដែលៗលើសិទ្ធិភាគច្រើនរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះត្រឹមត្រូវ ដែលបណ្តាលឱ្យមានកំហុសជាច្រើនក្នុងអំឡុងពេលនៃការជំនុំជម្រះ។ ការចោទប្រកាន់របស់គាត់អំពីភាពលម្អៀងបានពន្លាតបន្ថែមដល់ការបំបែកសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង។ គាត់បានអះអាងថា អានុភាពត្រួតគ្នាកំហុសទាំងនេះ បានធ្វើឱ្យការជំនុំជម្រះទាំងមូលទៅជាមិនយុត្តិធម៌ និងបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធការដាក់ពិរុទ្ធភាព និងទោសរបស់គាត់។

20. ខាងក្រោមនេះ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ពាក់ព័ន្ធទៅនឹងការអះអាងរបស់គាត់អំពីភាពលម្អៀងពីសំណាក់អង្គជំនុំជម្រះសាលាដំបូង ខៀវ សំផន បានលើកច្រំដែលនូវការចោទប្រកាន់របស់គាត់ពីមុនដែលថា សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានបុរេវិនិច្ឆ័យពិរុទ្ធភាពរបស់គាត់ក្នុងសំណុំរឿង ០០២/០២ និងបានអះអាងថា ជាការដែលពុំអាចធ្វើទៅបានសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនអើពើទៅលើការសម្រេចរបស់ខ្លួនក្នុងរឿងក្តីពីមុន នៅពេលសម្រេចថាតើត្រូវជំនុំជម្រះសំណុំរឿងបន្តបន្ទាប់ដូចម្តេច។ ទាំងនេះពុំមែនជាបញ្ហាថ្មីនោះទេ និងកន្លងមកជាកម្មវត្ថុនៃសំណើរបស់ ខៀវ សំផន សុំដិតចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលក្នុងឆ្នាំ ២០១៤ និង ២០១៩ ផ្សេងៗគ្នា។ ក្រុមប្រឹក្សានៃចៅក្រមដែលត្រូវបានជ្រើសតាំងជាពិសេសបានពិចារណាពេញលេញ និងបានបដិសេធការចោទប្រកាន់អំពីភាពលម្អៀងនេះ។ ដោយសារពុំមានអំណះអំណាងថ្មីដែលមានមូលដ្ឋានគ្រប់គ្រាន់គាំទ្រការជំទាស់សច្ចធារណ៍នៃអនាគតិរបស់ចៅក្រម អំណះអំណាងនេះត្រូវបដិសេធចោលដោយពុំចាំបាច់ពិនិត្យបន្ថែមទៀត។

21. ការចោទប្រកាន់បន្ថែមទៀតរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងតាមរយៈការពិនិត្យភស្តុតាងដែលនេះបានធ្វើឱ្យមានការរំលោភបំពានដទៃទៀតលើសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ត្រូវបានបដិសេធប្រហាក់ប្រហែលគ្នាដោយសារពុំមានមូលដ្ឋានគាំទ្រ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។

**<u>ការចោទប្រកាន់កំហុសទាក់ទងទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ</u>**

22. ទាក់ទងទៅនឹងការចោទប្រកាន់របស់គាត់ស្ដីពី *វិសាលភាពនៃការជំនុំជម្រះ* ខៀវ សំផន បានលើកការជំទាស់សំខាន់ៗប្រាំចំណុចពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ និងការជំនុំជម្រះ ដូចជាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារៈ (i) កំណត់ចរិតលក្ខណៈនៃសំណើរបស់គាត់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរថាជា អញ្ញត្រកម្មដាក់ឃឹតពេលតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង និងបានយល់ឃើញថា អញ្ញត្រកម្មនេះពុំអាចទទួលយកបាន (ii) បដិសេធលើអំណះអំណាងរបស់គាត់ពាក់ព័ន្ធទៅនឹងលក្ខណៈពុំគ្រប់គ្រាន់នៃបទចោទលើរូបគាត់ដោយសារខ្វះភាពច្បាស់លាស់ (iii) ការមិនអើពើលើអំណះអំណាងរបស់គាត់ដែលលើកឡើងថា អង្គជំនុំជម្រះពុំបានវិនិច្ឆ័យអង្គហេតុដែលពុំត្រូវបានទទួលយក និងពុំត្រូវបានកំណត់ផ្អែកច្បាប់ដោយសហចៅក្រមស៊ើបអង្កេត ដែលនេះបានបណ្ដាលឱ្យអង្គជំនុំជម្រះប្រព្រឹត្តហួសវិសាលភាពនៃការជំនុំជម្រះ (iv) ការចេញសាលក្រមផ្អែកលើអង្គហេតុដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចរាល់ហើយក្នុងសំណុំរឿង ០០២/០១ ឬលើអង្គហេតុដែលអង្គជំនុំជម្រះបានដកចេញពីសំណុំរឿង ០០២/០២ និងអង្គហេតុសម្រាប់បញ្ចប់កិច្ចដំណើរការនីតិវិធី និង (v) ពិចារណាលើ"ភស្តុតាងដែលពាក់ព័ន្ធ ប៉ុន្តែនៅក្រៅវិសាលភាព"អំពីអង្គហេតុដែលអង្គជំនុំជម្រះពុំតម្រូវឱ្យធ្វើការជំនុំជម្រះ។ ខាងក្រោមនេះជាការសង្ខេបការយល់ឃើញអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធទៅនឹងការជំទាស់ទាំងប្រាំនោះតាមលំដាប់លំដោយ។

23. ពាក់ព័ន្ធទៅនឹងអំណះអំណាងទីមួយរបស់គាត់ អង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា ដោយសារ ខៀវ សំផន បានជំទាស់ទៅនឹងវិសាលភាពជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើការចោទប្រកាន់កំហុសផ្នែកនីតិវិធីក្នុងដីកាដំណោះស្រាយ ពុំមែនលើយុត្តាធិការរបស់ អ.វ.ត.ក. ដូចនេះការជំទាស់របស់គាត់ពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការដាច់ខាត និងអាស្រ័យលើការកែតម្រូវតាមរយៈការជូនដំណឹងគ្រប់គ្រាន់អំពីបទចោទ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសក្នុងការបញ្ជាក់ថា អញ្ញត្រកម្មរបស់ ខៀវ សំផន ត្រូវស្ថិតក្រោមកាលបរិច្ឆេទដែលបានកំណត់ក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង។

24. ចំពោះអំណះអំណាងទីពីរ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងនូវសារណារបស់គាត់ពាក់ព័ន្ធទៅនឹងបទចោទពុំគ្រប់គ្រាន់ប្រឆាំងនឹងគាត់ ដោយសារកង្វះភាពច្បាស់លាស់ ហើយសម្រាប់ហេតុផលពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។

25. ចំពោះអំណះអំណាងទីបី អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ក្នុងការកំណត់នូវវិសាលភាពនៃការជំនុំជម្រះលើអង្គហេតុដែលមានក្នុងដីកាដំណោះ

ស្រាយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើអំណះអំណាងផ្នែកអង្គហេតុ និងអង្គច្បាប់របស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង និងយល់ឃើញថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ ហើយសម្រាប់ហេតុផលពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកានេះ។

26. ចំពោះអំណះអំណាងទីបួន អង្គជំនុំជម្រះតុលាការកំពូលពុំជឿជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារការចេញសាលក្រមផ្អែកលើអង្គហេតុដែលអង្គជំនុំជម្រះបានវិនិច្ឆ័យរួចហើយក្នុងសំណុំរឿង ០០២/០១ ឬអង្គហេតុដែលអង្គជំនុំជម្រះបានដកចេញពីសំណុំរឿង ០០២/០២ និងសម្រាប់ការបញ្ចប់កិច្ចដំណើការនីតិវិធីនោះទេ ហើយសម្រាប់ហេតុផលពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកានេះ។

27. ចុងក្រោយ ចំពោះអំណះអំណាងទីប្រាំដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារការអនុវត្តវិធីសាស្ត្រ"ផ្អែកលើប្រវត្តិសាស្ត្រ"ក្នុងការពិចារណាលើ"ភស្តុតាងក្រៅវិសាលភាព ប៉ុន្តែជាប់ពាក់ព័ន្ធ"អំពីអង្គហេតុដែលអង្គជំនុំជម្រះពុំតម្រូវឱ្យជំនុំជម្រះ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះអាចសំអាងទៅលើភស្តុតាងក្រៅវិសាលភាពនៃយុត្តាធិការពេលវេលា ឬភូមិសាស្ត្រនៃដីកាដំណោះស្រាយសម្រាប់គោលបំណងតិចតួចក្នុងការបំភ្លឺបរិបទណាមួយ ដោយបង្ហាញតាមរយៈការសន្និដ្ឋានអំពីធាតុផ្សំនៃអំពើល្មើសដែលបានកើតឡើងក្នុងអំឡុងពេលនោះ ឬបង្ហាញនូវលំនាំនៃអំពើគិតទុកជាមុន។

## ***ការចោទប្រកាន់កំហុសពាក់ព័ន្ធនៅនឹងបទឧក្រិដ្ឋជាមូលដ្ឋាន***

28. ទាក់ទងទៅនឹងផ្នែកយល់ឃើញពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរឿងក្តីប្រឆាំងនឹង ខៀវ សំផន ដូចជា បទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។

### ***អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ***

29. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវបទដ្ឋានអត្ថនោម័តិនៃ *ចេតនាប្រយោល* នៅពេលវាយតម្លៃលើអង្គហេតុពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានធ្វើឡើងក្នុងសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះតុលាការកំពូលបានតម្កល់នៅបណ្តឹងសាទុក្ខក្នុងរឿងក្តីនោះ។ ខៀវ សំផន បានអះអាងថា បទដ្ឋាននេះពុំត្រឹមត្រូវដោយសារពុំមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និងបន្ថែមថា គាត់ពុំអាចដឹងជាមុនបានអំពីការ

កំណត់និយមន័យនោះថា មានច្បាប់ចែង ឬជាបទល្មើសនៅពេលនោះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពុំយល់ស្របជាមួយលើចំណុចនេះ និងសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុស។

30. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំងដែលបានផ្អែកក្នុងផ្នែកខ្លះលើអំពើអសកម្មល្មើស ដោយគ្មានការបង្កើតការយល់ឃើញជាមុនថា មានកាតព្វកិច្ចត្រូវធ្វើដូច្នោះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំមានកំហុស។

31. *បញ្ហាថាតើ អំពើមនុស្សឃាតត្រូវបានបង្ហាញនៅការដ្ឋានខាងក្រោមនេះ ដែរ ឬទេ៖* (i) *សហករណ៍ត្រាំកក់* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយបានយល់ឃើញថា មានមនុស្សស្លាប់ដោយសារការអត់អាហារ និងការខ្វះការថែទាំជាមូលដ្ឋានផ្នែកវេជ្ជសាស្ត្រនៅសហករណ៍ត្រាំកក់ និងមានកំហុសក្នុងការយល់ឃើញថា កម្រិតដែលជាលក្ខខណ្ឌតម្រូវត្រូវបានបង្ហាញ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (ii) *ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើបញ្ហាថាតើ អាជ្ញាធរបានប្រព្រឹត្តក្នុងកម្រិតដែលជាលក្ខខណ្ឌតម្រូវនៃចេតនាពាក់ព័ន្ធទៅនឹងការស្លាប់មនុស្សនៅការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ដោយសារមានកត្តាដែលហួសពីការគ្រប់គ្រងរបស់ពួកគេដែលបាននាំទៅរកលក្ខខណ្ឌបណ្តាលឱ្យមានមនុស្សស្លាប់នៅទីនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលបានវិភាគអំណះអំណាងនេះ និងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (iii) *ការដ្ឋានធ្វើការទំនប់១មករា* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើមនុស្សឃាតបានកើតឡើងនៅការដ្ឋានធ្វើការទំនប់១មករាដោយសារការដាក់លក្ខខណ្ឌការរស់នៅ និងធ្វើការងារ រួមទាំងកង្វះថ្នាំពេទ្យ និងថា អ្នកធ្វើការបានស្លាប់ដោយសារគ្រោះថ្នាក់នានា។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ថាវីបានដឹងថា ពុំមានស្បៀង និងថ្នាំពេទ្យគ្រប់គ្រាន់ និងនៅតែជម្រុញឱ្យពួកគេបំពេញលក្ខខណ្ឌការងារនោះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (iv) *ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការស្លាប់ដោយសារការដាក់លក្ខខណ្ឌនោះត្រូវបានប្រព្រឹត្តឡើងក្នុងកម្រិតដែលជាលក្ខខណ្ឌតម្រូវនៃចេតនា ពីព្រោះមានកត្តាដែលហួសពីការគ្រប់គ្រងរបស់ពួកគេដែលបានបង្កឱ្យ

មានលក្ខខណ្ឌបែបនោះកើតឡើងដែលបណ្តាលឱ្យមានមនុស្សស្លាប់។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។ (v) *__មន្ទីរសន្តិសុខភ្នំក្រោល__* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា មានការស្លាប់មនុស្សពីរនាក់បានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោលដែលនេះអាចស្មើនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អ្នកទីមួយគឺអ្នកជាប់ឃុំឈ្មោះ ហ៊ើស ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ត្រូវបានសម្លាប់ដោយសន្តិសុខដែលយាមនៅទីនោះ។ អ្នកទីពីរជាអ្នកជាប់ឃុំឈ្មោះ ទូច ដែលបានស្លាប់ដោយសារលក្ខខណ្ឌដ៏អាក្រក់នៃការឃុំឃាំងដែលគាត់បានទទួលរង។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានយល់ឃើញថា អំពើមនុស្សឃាតទាំងពីរនេះត្រូវបានបង្ហាញហួសពីវិមតិសង្ស័យ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងការស្លាប់របស់ ហ៊ើស និង ទូច ដោយសារបានផ្អែកដោយច្បាស់លាស់ទៅលើចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីដែលបានទទួលមរណភាព ដែល ខៀវ សំផន ពុំអាចសួរដេញដោលបាន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល។

### *ការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

32. *ការសម្លាប់រង្គាលជនជាតិចាមៈ* អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ដោយចេតនាជនជាតិចាមនៅមន្ទីរសន្តិសុខអូរត្រកួនក្នុងឆ្នាំ ១៩៧៧ និងមន្ទីរសន្តិសុខភូមិទ្រាក្នុងឆ្នាំ ១៩៧៨។ អង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញចំនួនជាក់លាក់របស់ជនរងគ្រោះ ប៉ុន្តែបានជឿជាក់ថា ជនស៊ីវិលជនជាតិចាមក្នុងចំនួនដ៏ច្រើនត្រូវបាននាំទៅមន្ទីរសន្តិសុខទាំងពីរនេះ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើមនុស្សឃាតនេះបំពេញតាមលក្ខខណ្ឌតម្រូវនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ និងជាផ្នែកនៃប្រតិបត្តិការសម្លាប់មនុស្សដូចគ្នា។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានស្រូបបញ្ចូលអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានសម្រេចដាក់ពិរុទ្ធភាពតែពីបទសម្លាប់រង្គាលប៉ុណ្ណោះ។ ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា ការសម្លាប់នោះបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលពុំចាត់ទុកការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ពុំសមហេតុផលឡើយ។ ខៀវ សំផន បានជំទាស់បន្ថែមទៀតលើបញ្ហាថាតើ លក្ខខណ្ឌអំពីតួលេខសម្រាប់ការសម្លាប់រង្គាលត្រូវបានបំពេញ ដែរ ឬយ៉ាងណា ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំអាចបង្ហាញនូវចំនួនជាក់លាក់របស់ជនរងគ្រោះ ប៉ុន្តែអង្គជំនុំជម្រះតុលាការ

កំពូលពិចារណាឃើញថា អង្គហេតុបានគាំទ្រការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្លាប់ក្នុងទ្រង់ទ្រាយធំបានកើតឡើង។ ចុងក្រោយ ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ មានចេតនាសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែរ ឬយ៉ាងណា ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

33. *ការសម្លាប់រង្គាលជនជាតិវៀតណាម៖* ខៀវ សំផន បានចោទប្រកាន់កំហុសជាច្រើនផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង និងបានលើកឡើងថា អំពើមនុស្សឃាត និងការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំអាចត្រូវបានបង្ហាញទាក់ទងទៅនឹងការសម្លាប់ទាំងនេះឡើយ។

34. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការសម្លាប់បានកើតឡើងនៅទីតាំងខាងលើ។ ទាក់ទងទៅនឹងបញ្ហាថាតើ ការសម្លាប់នេះអាចស្មើនឹងការសម្លាប់រង្គាល ដែរ ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយក្នុងការកំណត់តួលេខរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការសម្លាប់ដែលបានប្រព្រឹត្តឡើងក្នុងទីតាំងជាច្រើន ដោយសារការយល់ឃើញដែលថា ការសម្លាប់នោះគឺជាផ្នែកនៃប្រតិបត្តិការសម្លាប់មនុស្សតែមួយ។

### *ការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

35. ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ ការដាក់ឱ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដែរ ឬយ៉ាងណា និងបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែតម្រូវឱ្យជំនុំជម្រះលើការដាក់ឱ្យទៅជាទាសករនៅទីតាំងមួយកន្លែងប៉ុណ្ណោះ គឺ ក-១១ ក្នុងមន្ទីរសន្តិសុខភ្នំក្រោល និងថា ភស្តុតាងនៃការដាក់ឱ្យទៅជាទាសករនៅ ក-១១ ពុំមានលក្ខណៈគ្រប់គ្រាន់។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងបញ្ហានេះ។

### *ការនិរទេសក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

36. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេសជនជាតិវៀតណាមចេញពីសហករណ៍ស្រុកត្រាំកក់ និងខេត្តព្រៃវែង។

ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិវៀតណាមត្រូវបាននិរទេសចេញពីសហករណ៍ត្រាំកក់ឆ្លងកាត់ព្រំប្រទល់ជាតិ ព្រមទាំងខេត្តព្រៃវែង។ ខៀវ សំផន បានជំទាស់ផងដែរលើភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា មានចេតនានិរទេសជនជាតិវៀតណាម។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

*ការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

37. ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលត្រូវបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងការបង្ហាញបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្មជនជាតិចាមនៅភូមិទ្រា។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាមត្រូវបានធ្វើទារុណកម្មនោះ គឺជាការយល់ឃើញដែលគ្មានតុលាការអង្គហេតុសមហេតុផលណាមួយអាចធ្វើទៅបាននោះឡើយ។

*ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

38. ខៀវ សំផន បានអះអាងថា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ ១៩៧៥ ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឱ្យមានគោលបំណងដកបុគ្គលដែលត្រូវបានកំណត់គោលដៅចេញពីសហគមន៍ដែលពួកគេរស់នៅជាមួយចារីនោះ ឬចេញពីសង្គមមនុស្សជាតិផ្ទាល់។ ក្នុងសាលដីកាសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហានេះ និងបានសន្និដ្ឋានថា គោលបំណងនោះ ពុំមែនជាធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ។ ទោះជាយ៉ាងណាក្តី ខៀវ សំផន បានទទូចសុំឱ្យមានការអនុវត្តប្រាសចាកពីការយល់ឃើញដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានផ្អែកលើការវិភាគទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ។ ចំពោះបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធក្នុងការធ្វើដូច្នោះ។ ជាលទ្ធផល ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

39. ខៀវ សំផន បានចោទប្រកាន់ផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ក្នុងការកំណត់ចរិតលក្ខណៈលើការប្រព្រឹត្តដូចគ្នាៗជាពិសេសទៅលើក្រុមបុគ្គលមួយប្រភេទថា ជាការរើសអើងជាក់ស្តែង។ គាត់បានអះអាងថា ការរើសអើងដោយប្រយោល គឺជាគោលគំនិតថ្មីៗនៃសិទ្ធិមនុស្សដែលពុំ

ត្រូវបានចាត់ទុកថា ជាការរើសអើងជាក់ស្តែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥។ ទាក់ទងទៅនឹងការអះអាងនេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានជាសង្ខេបដូចខាងក្រោម៖

### *ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម*

40. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិចាមត្រូវបានកំណត់គោលដៅផ្អែកលើមូលហេតុនយោបាយ និងត្រូវបានដកចេញដើម្បីបំបែកសហគមន៍របស់ពួកគេ។ ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញនេះ និងបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការបង្ហាញថា ការផ្លាស់ទីប្រជាជនបានប៉ះពាល់ជាពិសេស ឬយ៉ាងហោចណាស់ជាចម្បងទៅលើជនជាតិចាម និងដូច្នេះ ជាការរើសអើង។ ប្រហាក់ប្រហែលគ្នានេះដែរ ខៀវ សំផន បានអះអាងថា ពុំមានភស្តុតាងបង្ហាញថា ក្នុងអំឡុងពេលនៃការផ្លាស់ទីនោះ ជនជាតិចាមត្រូវបានប្រព្រឹត្តទៅលើខុសប្លែកពីអ្នកដទៃទៀតដែលតាមការអះអាងរបស់គាត់ គឺជាបទដ្ឋានដែលអង្គជំនុំជម្រះតុលាការកំពូលបានប្រើប្រាស់ក្នុងសំណុំរឿង ០០២/០១ ទាក់ទងទៅនឹង"ប្រជាជនថ្មី"។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន បានបកស្រាយពុំត្រឹមត្រូវលើយុត្តិសាស្ត្រនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានផ្លូវច្បាប់ត្រឹមត្រូវក្នុងការកំណត់ថាតើ ការធ្វើទុក្ខបុកម្នេញបានកើតឡើង ដែរ ឬយ៉ាងណា។ ខៀវ សំផន បានជំទាស់ផងដែរទៅលើបញ្ហាថាតើ ធាតុផ្សំអត្តនោម័តិត្រូវបានបង្ហាញត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង ដែរ ឬយ៉ាងណា និងបានអះអាងថា ពុំមានមូលដ្ឋានរើសអើងសម្រាប់ការផ្លាស់ទីជនជាតិចាមឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំណះអំណាងនេះខកខានក្នុងការបង្ហាញថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះមានលក្ខណៈពុំសមហេតុផល។ ខៀវ សំផន ចុងក្រោយបានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើបញ្ហាថាតើ ភាពធ្ងន់ធ្ងរនៃអំពើរើសអើងអាចស្មើនឹងការធ្វើទុក្ខបុកម្នេញ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា អំពើនេះឈានដល់កម្រិតដែលជាលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលអាចស្មើនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម ត្រូវបដិសេធចោល។

### *ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើ"សត្រូវពិត ឬតាមការសន្មត"*

41. ខៀវ សំផន បានជំទាស់ទៅនឹងភាពដែលអាចកំណត់នៃក្រុមគោលដៅថាជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា"ទាក់ទងទៅនឹងការយល់ឃើញនៃការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខអូរកន្សែង។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហានេះ

ក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ និងបានសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយត្រូវបានយល់ថា ជាការរួមបញ្ចូលស្ថានការណ៍ដែលចារីបានកំណត់គោលដៅលើក្រុមតាមការសន្មតទូលំទូលាយ ដោយគ្មានការអង្កេតមើលទស្សនៈនយោបាយរបស់បុគ្គលដែលពាក់ព័ន្ធនោះឡើយ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល"បានបញ្ជាក់យកលទ្ធភាពថា ការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចកំណត់គោលដៅលើក្រុមប្រមូលផ្តុំដោយគ្មានការកំណត់អត្តសញ្ញាណ ឬរបៀបវារៈរួមគ្នាឡើយ"។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា "សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" ពុំមែនជាក្រុមដែលអាចកំណត់បានគ្រប់គ្រាន់សម្រាប់ការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយឡើយ។

***ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយនៅសហករណ៍ និងមន្ទីរសន្តិសុខ***

42. (i) *<u>សហករណ៍ត្រាំកក់៖</u>* ខៀវ សំផន អះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការយល់ឃើញថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើទុក្ខបុកម្នេញនៅសហករណ៍ត្រាំកក់ដោយសារមូលហេតុនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។ (ii) *<u>ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម៖</u>* ខៀវ សំផន បានលើកឡើងថា អំពើនៃការធ្វើទុក្ខបុកម្នេញដែលចោទជាបញ្ហានេះនៅការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ត្រឹមតែជាការដកប្រជាជនថ្មីចេញពីតួនាទីដឹកនាំ និងការដែលពួកគេត្រូវបានតាមដានដោយប្រជាជនមូលដ្ឋានប៉ុណ្ណោះ ដែលតាមការអះអាងរបស់គាត់ថា ពុំគ្រប់គ្រាន់ក្នុងការយល់ឃើញថា សិទ្ធិជាមូលដ្ឋាននោះត្រូវបានរំលោភបំពាន ឬថា លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដើម្បីបង្កើតឱ្យបានជាការធ្វើទុក្ខបុកម្នេញក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញឡើយ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។ (iii) *<u>ការដ្ឋានធ្វើការទំនប់១មករា៖</u>* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស (១) អង្គហេតុក្នុងការសន្និដ្ឋានថា អត្ថិភាពនៃការរើសអើងលើប្រជាជនថ្មីនៅការដ្ឋានធ្វើការទំនប់១មករា (២) អង្គច្បាប់ដោយសារការបញ្ជាក់នូវអត្ថិភាពនៃសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នា (៣) កំហុសអង្គច្បាប់ និងអង្គហេតុតាមរយៈការយល់ឃើញថា ការប្រព្រឹត្តទៅលើនោះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនថ្មីក្នុងការទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នា និង (៤) កំហុសអង្គច្បាប់ដោយសារការខកខានក្នុងការគូសបង្ហាញនូវកម្រិតដែលជាលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរដែលចាំបាច់ត្រូវបំពេញសម្រាប់អំពើជាមូលដ្ឋានដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើទុក្ខបុកម្នេញ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គ

ជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញអំពីអត្ថិភាពនៃសិទ្ធិទទួលបានការប្រព្រឹត្តទៅលើស្មើភាពគ្នានៅក្នុងច្បាប់សន្ធិសញ្ញា ឬទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានរំលោភបំពាន និងអាស្រ័យហេតុនេះបដិសេធការដាក់ពិរុទ្ធភាពលើគាត់ពីបទធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើប្រជាជនថ្មីនៅការដ្ឋានធ្វើការទំនប់១មករា។ ខៀវ សំផន បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើភស្តុតាងមិនគ្រប់គ្រាន់ក្នុងការយល់ឃើញថា អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរត្រូវបានធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅការដ្ឋានធ្វើការទំនប់១មករា។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។ (iv) *<u>មន្ទីរសន្តិសុខ ស-២១</u>៖* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើដែលកំណត់គោលដៅលើ"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" គឺជាការរើសអើងជាក់ស្តែង និងបានអះអាងថា ការចាប់ខ្លួនក្នុងទ្រង់ទ្រាយធំបានបង្ហាញថា នេះជាការមិនរើសមុខ។ គាត់បានអះអាងថា ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការធ្វើទុក្ខបុកម្នេញផ្អែកលើមូលហេតុនយោបាយដោយសារអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ពុំមានលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចកំណត់បានជាក់លាក់ត្រូវបានអនុវត្តក្នុងការកំណត់គោលដៅលើជនរងគ្រោះ។ ខៀវ សំផន បានអះអាងថា ភស្តុតាងក្នុងសំណុំរឿង ០០២/០២ គ្មានអ្វីខុសគ្នាដែលគាំទ្រការយល់ឃើញផ្សេងគ្នាក្នុងរឿងក្តីនេះទេ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ការពិតដែលថា ប្រជាជនត្រូវបានចាប់ខ្លួនក្នុងទ្រង់ទ្រាយធំពុំបានរារាំងការយល់ឃើញអំពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដរាបណាមានសមាជិកនៃក្រុមគោលដៅត្រូវបានចាប់ខ្លួន ដោយសារតែពួកគេស្ថិតក្នុងក្រុមគោលដៅនោះ។ ការបដិសេធរបស់អង្គជំនុំជម្រះតុលាការកំពូលនូវការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយក្នុងសំណុំរឿង ០០១ មានលក្ខណៈជាក់លាក់ចំពោះ ឌុច ប៉ុណ្ណោះ។ ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា អំពើនោះគឺជាការរើសអើង។ (v) *<u>មន្ទីរសន្តិសុខអូរកន្សែង</u>* ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការធ្វើទុក្ខបុកម្នេញបានកើតឡើងនៅមន្ទីរសន្តិសុខអូរកន្សែង និងថា ជាសំខាន់ ភស្តុតាងដែលបានសំអាងទៅលើនោះ ពុំបានបង្ហាញអំពីការប្រព្រឹត្តដោយរើសអើងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញនូវកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

*ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា*

43. អង្គជំនុំជម្រះសាលាដំបូងបានបង្កើតការយល់ឃើញផ្នែកអង្គច្បាប់ពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនាជាពីរផ្នែកក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង៖ ផ្នែកទីមួយជាពិសេសទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមនៅការដ្ឋានធ្វើការទំនប់១មករា និងទីពីរទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមទូទៅ។ ពាក់ព័ន្ធទៅនឹងការដ្ឋានធ្វើការទំនប់១មករា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អ្នកធ្វើការជនជាតិចាមបានទទួលរងការរើសអើងដោយសារពួកគេត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក ហាមឃាត់ការអធិដ្ឋាន និងការនិយាយភាសាកំណើតរបស់ខ្លួន។ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាមទូទៅ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការហាមឃាត់នានា និងការហាមឃាត់ផ្នែកវប្បធម៌ត្រូវបានដាក់កំហិត រួមទាំងការហាមឃាត់ការអធិដ្ឋានរាល់ថ្ងៃ ការបង្ខំឱ្យបរិភោគសាច់ជ្រូក ការបង្ខំឱ្យស្លៀកសំលៀកបំពាក់ និងកាត់សក់ខ្លីដូចជនជាតិខ្មែរ ការបង្ខំឱ្យនិយាយតែភាសាខ្មែរ និងការដុតគម្ពីរអាល់គូរ៉អាន និងការរុះរើវិហារអ៊ីស្លាម ឬប្រើប្រាស់សម្រាប់គោលបំណងមិនពាក់ព័ន្ធសាសនា។ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ការរឹតត្បិតនេះគឺជាការរើសអើង និងត្រូវបានប្រព្រឹត្តដោយចេតនាគិតទុកជាមុនក្នុងការរើសអើងលើជនជាតិចាមដោយសារតែការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ។

44. ខៀវ សំផន បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្ហាញថា អំពើរើសអើងមួយចំនួនបានកើតឡើងនៅការដ្ឋានធ្វើការទំនប់១មករា និងកន្លែងផ្សេងទៀតក្នុងកម្ពុជា។ គាត់បានអះអាងផងដែរថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការពិចារណាលើបញ្ហាថាតើ ការរឹតត្បិតលើសេរីភាពផ្នែកសាសនា ត្រូវបានអនុញ្ញាតក្នុងច្បាប់ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

45. ខៀវ សំផន បានអះអាងថា អំពើរើសអើងពុំមានអត្ថិភាព ដោយសារមានការអនុវត្តស្មើភាពគ្នាចំពោះប្រជាជនគ្រប់រូប។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការរើសអើងជាក់ស្តែងបានកើតឡើងនៅពេលមានលទ្ធផលមិនស្មើគ្នាសម្រាប់ក្រុមជាក់លាក់មួយតាមរយៈការអនុវត្តន៍ទូទៅនៃអំពើសកម្ម ឬអសកម្ម។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសណាមួយក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាតិចាម"ជាចម្បង និងជាពិសេសបានទទួលរងផលប៉ះពាល់"ដោយសារការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ ដូច្នេះមានអត្ថិភាពនៃការរើសអើងជាក់ស្តែង។

46. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា មានការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ពីព្រោះការរឹតត្បិតផ្នែកសាសនា និងវប្បធម៌ពុំបានរំលោភបំពានលើសិទ្ធិ

ណាមួយដែលអង្គជំនុំជម្រះសាលាដំបូងបានយោងទៅលើនៅក្នុងការយល់ឃើញផ្នែកច្បាប់របស់ខ្លួន និង បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា សិទ្ធិខាងសេរីភាពផ្នែកសាសនាត្រូវបាន រំលោភបំពានទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិចាមទូទៅ លើកលែងតែនៅការដ្ឋានធ្វើការទំនប់១មករា ប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា អង្គ ជំនុំជម្រះបានយល់ឃើញថា សិទ្ធិនៃសេចក្ដីថ្លៃថ្នូររបស់បុគ្គលត្រូវបានរំលោភបំពានដោយសារការរឹតត្បិត ផ្នែកសាសនា និងវប្បធម៌ដែលចោទជាបញ្ហានោះ និងថា ការយល់ឃើញនេះមានលក្ខណៈសមហេតុផល។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន។

47. ខៀវ សំផន បានជំទាស់ផងដែរទៅលើបញ្ហាថាតើ មានចេតនាក្នុងការរើសអើងផ្អែកលើមូលហេតុ សាសនា ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការ បង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

48. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការ ធ្វើទុក្ខបុកម្នេញផ្នែកសាសនាលើពុទ្ធសាសនិក ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់។ ជាពិសេស អង្គ ជម្រះសាលាដំបូងយល់ឃើញថា ព្រះសង្ឃពុទ្ធសាសនាជាង១០០អង្គត្រូវបានប្រមូលផ្ដុំនៅវត្តអង្គរកា និង ត្រូវបានបង្ខំឱ្យលាចាកសិក្ខាបទ។ អង្គជំនុំជម្រះបានពិចារណាឃើញថា ការសំដៅទៅលើព្រះសង្ឃថា ជា "ដង្កូវ" ឬ "ឈ្លើង" និងការប្រកាសបដិសេធសាសនាព្រះពុទ្ធថា ជាអបិយជំនឿ និងព្រះពុទ្ធបដិមា"គ្រាន់តែ ជាស៊ីម៉ង់ត៍" បានបង្ហាញនូវចេតនារើសអើងនៅពីក្រោយដំណើរការនោះ។ អង្គជំនុំជម្រះសាលាដំបូងបាន បញ្ជាក់បន្ថែមទៀតថា និមិត្តរូបតំណាងពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ និងវត្តអារាមត្រូវបានប្រើប្រាស់ សម្រាប់គោលបំណងមិនពាក់ព័ន្ធសាសនាទូទាំងស្រុកត្រាំកក់។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ភ ស្តុតាងបានបង្ហាញអំពីការលុបបំបាត់ទាំងស្រុងនូវការប្រតិបត្តិសាសនាព្រះពុទ្ធ ដែលនេះជា"ការវាយ ប្រហារជានិរន្តរ៍ និងតាមការរៀបចំប្រឆាំងនឹងសាសនា"ដែលត្រូវបានចាត់ទុកថា ពុំស្របជាមួយនឹងការអនុ វត្តន៍នៃបដិវត្ត។ ដោយផ្អែកលើការពិចារណាទាំងនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ផលប៉ះពាល់ផ្លូវ ចិត្ត និងចិត្តសាស្ត្រពីព្រឹត្តិការណ៍នេះបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងកម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែ លគ្នាទៅនឹងបទឧក្រិដ្ឋដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

49. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ការ ធ្វើទុក្ខបុកម្នេញផ្នែកសាសនា ត្រូវបានបង្ហាញ និងបានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹង ផលប៉ះពាល់ផ្លូវចិត្ត ឬរូបកាយដោយសារការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកឡើយ។ បន្ថែមលើនេះ គាត់

បានអះអាងថា ដោយសារគ្មានភស្តុតាងបង្ហាញអំពីការប្រព្រឹត្តដោយរើសអើងលើព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិក អ្នកទាំងនេះត្រូវបានប្រព្រឹត្តទៅលើដូចប្រជាជនដទៃទៀតដែរ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ពុំបានបង្ហាញកំហុសណាមួយពីសំណាក់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធបញ្ហានេះ។

## *ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍*

50. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍លើជនជាតិវៀតណាមត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង ខេត្តព្រៃវែង និងខេត្តស្វាយរៀង។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តឡើងជាផ្នែកនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាម "សម្រាប់ការចាត់ទុកជាសត្រូវពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស សម្រាប់ការនិរទេសនៅមុនខែ មេសា ឆ្នាំ ១៩៧៧ និងសម្រាប់ការកម្ទេចដោយសារជាក្រុមពូជសាសន៍ក្រោយមក" ពីព្រោះជនជាតិវៀតណាមត្រូវបានចាត់ទុកថា ជា"សត្រូវគ្រោះថ្នាក់បំផុតដល់របបកម្ពុជាប្រជាធិបតេយ្យ"។ ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ ការធ្វើទុក្ខបុកម្នេញផ្នែកពូជសាសន៍បានកើតឡើងនៅទីតាំងខាងលើ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញកំហុសពីសំណាក់អង្គជំនុំជម្រះសាលាដំបូង។

## *<u>អំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>*

51. ខៀវ សំផន បានជំទាស់ទៅនឹងបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើគោលការណ៍នីត្យានុកូលភាព ដែរ ឬយ៉ាងណា នៅពេលអង្គជំនុំជម្រះបានយល់ឃើញថា ជនជាប់ចោទអាចដឹងជាមុនបានថា មានច្បាប់ចែង និងជាបទល្មើសក្នុងន័យទូទៅថា អំពើអមនុស្សធម៌ដទៃទៀតនេះអាចដាក់ទោសបានក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥។ យោងតាម ខៀវ សំផន ថា ជាការពុំគ្រប់គ្រាន់ក្នុងការនិយាយថា អំពើអមនុស្សធម៌ដទៃទៀតអាចដឹងជាមុនបានថា មានច្បាប់ចែង ដោយសារអំពើប្រភេទនេះអាចគ្របដណ្តប់ការប្រព្រឹត្តច្រើនប្រភេទ។ ផ្ទុយទៅវិញ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងគប្បីបានកំណត់ជាក់លាក់នូវការប្រព្រឹត្តដែលចោទជាបញ្ហានេះ និងបានពិនិត្យលើបញ្ហាថាតើ អំពើនេះត្រូវបានកំណត់និយមន័យថា ជាបទល្មើសនៅពេលនោះ ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខៀវ សំផន បានយល់ពុំត្រឹមត្រូវអំពីការអនុវត្តគោលការណ៍នីត្យានុកូលភាពពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀត។ អ្វីដែលតម្រូវគឺថាតើ ជនជាប់ចោទអាចដឹងជាមុនបាននូវ

អំពើអមនុស្សធម៌ដទៃទៀតប្រភេទនេះថា មានច្បាប់ចែង និងជាបទល្មើស ដែរ ឬទេ ដែលអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងករណីនេះ។ ជាលទ្ធផល ពុំមានកំហុស។

52. ខៀវ សំផន បានអះអាងផងដែរថា អំពើនោះត្រូវតែរំលោភបំពានការហាមឃាត់ជាក់លាក់ដែលមានចែងក្នុងលិខិតុបករណ៍ស្ដីពីសិទ្ធិមនុស្សដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀត។ ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តតាមវិធីសាស្ត្រដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងនៃ តុលាការ ICTY ក្នុងរឿងក្ដី *Kupreškić* "ដែលបានភ្ជាប់ទំនាក់ទំនង'អំពើអមនុស្សធម៌ដទៃទៀត'ទៅនឹងអំពើដែលរំលោភបំពានលើសិទ្ធិជាមូលដ្ឋានពាក់ព័ន្ធទៅនឹងមនុស្សជាតិ ដូចបានកំណត់ក្នុងលិខិតុបករណ៍គតិយុត្តអន្តរជាតិ"។ ទោះជាយ៉ាងណាក្ដី អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា ពុំមានលក្ខខណ្ឌតម្រូវថា អំពើជាក់លាក់ត្រូវតែជាបទល្មើសច្បាស់លាស់ក្រោមច្បាប់អន្តរជាតិឡើយ ដោយសារនេះអាចធ្វើឱ្យគោលគំនិតនៃអំពើអមនុស្សធម៌ដទៃទៀតដែលជាប្រភេទមិនជាក់លាក់លែងមានភាពចាំបាច់។ អាស្រ័យហេតុនេះ សារណារបស់ ខៀវ សំផន ពាក់ព័ន្ធបញ្ហានេះ ត្រូវបដិសេធចោល។

### *ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ*

53. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ត្រូវបានបង្ហាញនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញដោយត្រឹមត្រូវថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ បានកើតឡើងនៅត្រាំកក់ ក្រាំងតាចាន់ និងភ្នំក្រោល។

### *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

54. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍គឺជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានបង្កើតឡើង និងបានអនុវត្តដើម្បីសម្រេចគោលដៅបដិវត្តសង្គមនិយមក្នុងកម្ពុជា។ គោលនយោបាយនេះជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានកំណត់ចរិតលក្ខណៈដោយអង្គជំនុំជម្រះថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការ

រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន មានពិរុទ្ធភាពដោយសារបានប្រព្រឹត្តអំពើអមនុស្សធម៌ដទៃទៀតទាំងនេះដែលជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួម។

55. ខៀវ សំផន បានជំទាស់ទៅនឹងការដាក់ពិរុទ្ធភាពលើគាត់សម្រាប់បទឧក្រិដ្ឋទាំងនេះដោយផ្អែកលើបទបញ្ញានៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ និងបានអះអាងថា ជាការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព និងបានជំទាស់ទៅនឹងការយល់ឃើញផ្អែកអង្គហេតុ និងជំទាស់ទៅនឹងភាពធ្ងន់ធ្ងរនៃអំពើនោះ។ សហព្រះរាជអាជ្ញាបានធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានដកជនរងគ្រោះជាបុរសនៃការរំលោភសេពសន្ថវៈចេញពីបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

*ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

56. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានសំអាងទៅលើរឿងក្ដីយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិក្នុងការបង្ហាញនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងខកខានក្នុងការបញ្ជាក់ថាតើ អំពើនោះបានរំលោភបំពានសិទ្ធិជាមូលដ្ឋាន ដែរ ឬយ៉ាងណា និងខកខានក្នុងការពិចារណាលើនីត្យានុកូលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបដទៃទៀតស្ដីពីគ្រួសារ និងក្នុងកម្ពុជាពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ និងខកខានក្នុងការពិចារណាត្រឹមត្រូវលើគោលការណ៍ស្ដីពី *អត្តិភាពប្រហាក់ប្រហែលគ្នា* ក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងពេលជម្លោះដទៃទៀត។ សម្រាប់សំអាងហេតុពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទាំងអស់នេះ។

57. ខៀវ សំផន បានអះអាងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងវិធីសាស្ត្ររបស់ខ្លួនក្នុងការពិចារណាលើការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សហព្រះរាជអាជ្ញាបានប្ដឹងសាទុក្ខលើអ្វីដែលខ្លួនបានអះអាងថា ជាកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាពិសេស សហព្រះរាជអាជ្ញាបានយោងទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីធាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀតពាក់ព័ន្ធទៅនឹងអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានអះអាងថា អង្គជំនុំជម្រះ

សាលាដំបូងខកខានក្នុងការបង្កើតការយល់ឃើញសមស្របពាក់ព័ន្ធទៅនឹងបទពិសោធន៍នៃជនរងគ្រោះជាបុរសនៃឧក្រិដ្ឋកម្មនេះ។

58. អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការព្យាយាមកំណត់ធាតុផ្សំនៃការរំលោភសេពសន្ថវៈនៅក្នុងការវិភាគរបស់ខ្លួន។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីបានពិចារណាតែលើអំពើដែលត្រូវបានចោទប្រកាន់ដែលបានកើតឡើង ដែលជាអំពើនៃការរួមភេទដោយបង្ខំរវាងជនរងគ្រោះទាំងបុរស និងស្ត្រីដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញបន្ថែមទៀតថា ការប្រព្រឹត្តដោយបង្ខំនេះ បានរំលោភបំពានច្បាស់ណាស់លើសិទ្ធិស្តីពីបូរណភាពផ្នែករូបកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាធរមាននៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ និងមានលក្ខណៈធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានោះ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អំពើនេះដែលត្រូវបានពិពណ៌នាត្រឹមត្រូវថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំស្ថិតក្នុងវិសាលភាពនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលបំភ្លឺថា ជនរងគ្រោះនៃការរួមភេទដោយបង្ខំមានទាំងបុរស និងស្ត្រី។ ផ្អែកតាមការវិភាគនេះ អង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងកំហុសក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះជនរងគ្រោះជាបុរស។

*លក្ខណៈ និងការអនុវត្តន៍គោលនយោបាយរៀបអាពាហ៍ពិពាហ៍*

59. ខៀវ សំផន បានលើកការជំទាស់ផ្អែកអង្គហេតុផ្សេងៗទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីគោលបំណងនៃគោលនយោបាយរៀបអាពាហ៍ពិពាហ៍ ដូចជា៖ ការបង្កើនប្រជាជន និងគ្រប់គ្រងទំនាក់ទំនងផ្លូវភេទ។ គាត់បានចោទប្រកាន់អំពីភាពផ្ទុយគ្នារវាងគោលបំណងពីរនោះ និងបានអះអាងថា ការរឹតត្បិតទំនាក់ទំនងផ្លូវភេទបុរស និងស្ត្រី គឺផ្ទុយគ្នាទៅនឹងគោលបំណងបង្កើនចំនួនប្រជាជន។ ខៀវ សំផន បានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលការណ៍បក្សកុម្មុយនីស្តកម្ពុជានៃការស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តពុំត្រឹមត្រូវជាក់ស្តែង ព្រមទាំងការយល់ឃើញអំពីការរៀបអាពាហ៍ពិពាហ៍របស់អតីតយោធិនពិការ និងពិធីរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធរាល់ការជំទាស់ទាំងអស់នេះ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកាជាលាយលក្ខណ៍អក្សរនេះ។

60. ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា ពុំមានគោលនយោបាយនៃរួមភេទដោយបង្ខំ ព្រមទាំងការបដិសេធរបស់គាត់ដែលថា ការរួមភេទត្រូវបានបង្ខំ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់នៅក្នុងសាលដីកាជាលាយលក្ខណ៍អក្សរនេះ ។

61. ខៀវ សំផន បានជំទាស់ផងដែរទៅលើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបទបញ្ជាចេញពីថ្នាក់លើឱ្យរៀបចំការរៀបអាពាហ៍ពិពាហ៍នេះ របាយការណ៍ស្តីពីការរៀបអាពាហ៍ពិពាហ៍ទៅថ្នាក់លើ និងរបាយការណ៍ស្តីពីការតាមដានការរួមដំណេកនៃការរៀបអាពាហ៍ពិពាហ៍ ព្រមទាំងការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនគាត់នៅក្នុងបទបញ្ជារៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ក្នុងករណីដ៏ច្រើនលើសលុប បានបំភ្លៃសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងភស្តុតាងទាក់ទងនឹងបញ្ហានេះ។ អាស្រ័យហេតុនេះ សារណារបស់គាត់ត្រូវបដិសេធចោល។

### *ការយល់ឃើញផ្នែកអង្គច្បាប់ស្តីពីធាតុផ្សំអំពើអមនុស្សធម៌ដទៃទៀត*

62. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា អំពើដែលត្រូវបានចោទប្រកាន់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងជាការរំលោភសេពសន្ថវៈក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើតឡើង។ ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការឈឺចាប់ផ្នែករូបកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ បានបង្កទៅលើបុគ្គលតាមរយៈការគំរាមកំហែងបង្ខិតបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកដែលខ្លួនពុំដែលស្គាល់ និងការភ័យខ្លាចត្រូវបានបង្កឡើងដើម្បីដាក់សម្ពាធលើពួកគេឱ្យរួមដំណេកការរៀបអាពាហ៍ពិពាហ៍ និងបានយល់ឃើញថា អំពើនោះត្រូវបានប្រព្រឹត្តដោយចេតនា។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អំពើដែលត្រូវបានចាត់ទុកថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបង្ហាញ និងបានបំពេញតាមលក្ខខណ្ឌនៃអំពើអមនុស្សធម៌ដទៃទៀត។ ពាក់ព័ន្ធទៅនឹងអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការរំលោភសេពសន្ថវៈបានកើតឡើងពាក់ព័ន្ធទៅនឹងជនរងគ្រោះជាស្ត្រី និងបានបង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត។ ជាលទ្ធផល ផ្អែកតាមលក្ខណៈដែលធ្វើឱ្យប៉ះពាល់ដល់ជនរងគ្រោះជាបុរស ការរួមភេទដោយបង្ខំក៏ជាអំពើអមនុស្សធម៌ផងដែរ។

63. ទោះជាយ៉ាងណាក្តី ទាក់ទងទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ផ្អែកលើកាលៈទេសៈ ពួកគេពុំអាចត្រូវបានចាត់ទុកថា ជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើបញ្ហាថាតើ ជនរងគ្រោះជាបុរសនោះបានឆ្លងកាត់បទពិសោធន៍នៃអំពើហិង្សាផ្លូវភេទក្នុង

កម្រិតធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នា ដែរ ឬយ៉ាងណា។ អង្គជំនុំជម្រះបានសន្និដ្ឋានថា បើទោះបីជាពួកគេបានឆ្លងកាត់អំពើហិង្សាផ្លូវភេទដែលជាការរំលោភបំពានលើសេចក្តីថ្លៃថ្នូររបស់មនុស្សក៏ដោយ ក៏ពុំមានភស្តុតាងបង្ហាញច្បាស់លាស់ពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់លើជនរងគ្រោះជាបុរសឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ធាតុផ្សំនៃអំពើអមនុស្សធម៌ដទៃទៀតពុំត្រូវបានបង្ហាញទាក់ទងទៅនឹងជនរងគ្រោះជាបុរសនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសន្និដ្ឋានថា ជាក់ស្តែងមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រសេចក្តីសន្និដ្ឋានថា ជនរងគ្រោះជាបុរសបានឆ្លងកាត់ផលប៉ះពាល់ប្រហាក់ប្រហែលគ្នាទៅនឹងជនរងគ្រោះជាស្ត្រី ដែលបានឆ្លងកាត់ការបង្ខំឱ្យរួមភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាលទ្ធផលឃើញថា ការរួមភេទដោយបង្ខំគឺជាអំពើអមនុស្សធម៌ចំពោះជនរងគ្រោះជាបុរស ដែលជាកត្តាមួយអង្គជំនុំជម្រះបានពិចារណា និងទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះជនរងគ្រោះជាបុរស។

64. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសនៅក្នុងការយល់ឃើញដែលបានបង្កើតឡើងស្តីពីធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការខកខានក្នុងការពិចារណាលើបរិបទនៃការរៀបអាពាហ៍ពិពាហ៍ផ្សំផ្គុំតាមប្រពៃណី ដែលតាមការលើកឡើងរបស់គាត់ មានលក្ខណៈដូចគ្នាទៅនឹងការរៀបអាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងក្នុងការយល់ឃើញដែលអង្គជំនុំជម្រះបានបង្កើតឡើងស្តីពីការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្តក្នុងករណីបុគ្គលផ្សេងៗនោះ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងនីមួយៗនេះ។ បន្ថែមលើនេះ ការជំទាស់របស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងភស្តុតាងដែលបង្ហាញអំពីបទពិសោធន៍បុគ្គលដែលឆ្លងកាត់ព្យសនកម្មនោះ។ ខៀវ សំផន បានលើកការសន្និដ្ឋានមួយបែបផ្សេងដែលពុំមានភស្តុតាងគាំទ្រ និងបានបំភ្លៃភស្តុតាង និងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ឬត្រឹមតែមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានការលើកបង្ហាញកំហុសណាមួយឡើយ។

65. បន្ទាប់មក ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីជនរងគ្រោះជាស្ត្រីនៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះពាក់ព័ន្ធបញ្ហានេះ។ សហព្រះរាជអាជ្ញាបានជំទាស់ផងដែរទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះ

សាលាដំបូងពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរសក្នុងបរិបទនៃអំពើដែលត្រូវបានចោទប្រកាន់ថា ជាការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ អង្គជំនុំជម្រះតុលាការកំពូលរំឮកការយល់ឃើញរបស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការព្យាយាមបង្ហាញនូវធាតុផ្សំនៃការរំលោភសេពសន្ថវៈពាក់ព័ន្ធទៅនឹងជនរងគ្រោះជាបុរស ផ្ទុយទៅវិញគប្បីបានពិចារណាតែលើបញ្ហាថាតើអំពើដែលត្រូវបានចោទនៃការរួមភេទដោយបង្ខំនោះ បានកើតឡើងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែរ ឬយ៉ាងណា។ ក្រោយពីបានពិនិត្យលើភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រសេចក្តីសន្និដ្ឋានដែលថា អំពើដែលត្រូវបានចោទនេះនៃការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាក់ស្តែងបានកើតឡើង។

66. ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តកំហុសនៅក្នុងការយល់ឃើញរបស់ខ្លួនស្តីពីព្យសនកម្មដែលត្រូវបានឆ្លងកាត់ដោយជនរងគ្រោះជាស្ត្រីជាច្រើននាក់ និងបានចោទប្រកាន់កំហុសផងដែរក្នុងការខកខានពិចារណាលើភស្តុតាមួយចំនួនដទៃទៀត។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងទាំងនេះពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ខៀវ សំផន បានបំភ្លៃភស្តុតាង ឬត្រឹមតែមិនយល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគ្មានការបង្ហាញកំហុសណាមួយឡើយ។

*អំពើប្រល័យពូជសាសន៍*

67. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាតិវៀតណាមគឺជាក្រុមពូជសាសន៍ជាតិពន្ធុដែលត្រូវបានការពារក្នុងអំឡុងពេលនៃយុត្តាធិការដីកាបញ្ជូនទៅជំនុំជម្រះ។ បន្ទាប់ពីបានកំណត់ថា ក្រុមជនជាតិវៀតណាមស្ថិតក្នុងចំណោមជនរងគ្រោះនៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត និងការសម្លាប់រង្គាល និងថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅលើពួកគេដោយសារពួកគេជាជនជាតិវៀតណាម ដោយមានចេតនាកម្ទេចក្រុមនេះ អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា អំពើប្រល័យពូជសាសន៍ត្រូវបានបង្ហាញ។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ការសម្លាប់ជនជាតិវៀតណាមបានកើតឡើង ឬថាការសម្លាប់នៅអូរកន្សែង មន្ទីរស-២១ និងក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យរួមទាំងផែអូរឈើទាល ត្រូវបានប្រព្រឹត្តទៅលើសមាជិកនៃក្រុមដែលត្រូវបានការពារ។ គាត់បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារខកខានក្នុងការកំណត់

ថាតើ មានចេតនាបំផ្លាញក្រុមដែលត្រូវបានការពារ“ទាំងមូល ឬផ្នែកខ្លះ” ព្រមទាំងបញ្ហាថាតើមានចេតនាបំផ្លាញក្រុមដែលត្រូវបានការពារនោះ ដែរ ឬយ៉ាងណា។

68. អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញមានកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ដែនទឹកកម្ពុជាប្រជាធិបតេយ្យ ខេត្តកំពង់ឆ្នាំង វត្តខ្សាច់ និងខេត្តក្រចេះ។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ត្រឹមត្រូវនូវច្បាប់ជាធរមានពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍។ បន្ថែមលើនេះ ក្នុងការកំណត់ថា ធាតុផ្សំអត្តនោម័តិនៃអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់ត្រូវបានបង្ហាញ អង្គជំនុំជម្រះសាលាដំបូងបានសំអាងត្រឹមត្រូវលើកត្តានានាបន្ថែមទៅលើទំហំនៃអំពើឃោរឃៅ ដូចជា អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅលើជនជាតិវៀតណាមក្នុងការចាត់ទុកជាសត្រូវពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អំណះអំណាងរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រ និងត្រូវបដិសេធចោលពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍។ សម្រាប់សំអាងហេតុពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។

## <u>**ការចោទប្រកាន់កំហុសឆ្គងទាក់ទងទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល**</u>

### ***តួនាទី និងការទទួលខុសត្រូវរបស់ ខៀវ សំផន ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ***

69. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទី និងការទទួលខុសត្រូវក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការយល់ឃើញជាច្រើននេះបូករួមជាមួយនឹងភស្តុតាងដទៃទៀត បង្កើតបានជាមូលដ្ឋាននៃការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការរួមចំណែក ចេតនា និងការដឹងរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា អំណះអំណាងជាច្រើនរបស់ ខៀវ សំផន ពុំមានមូលដ្ឋានគាំទ្រ។ គាត់ត្រឹមតែលើកការបកស្រាយជាជម្រើសមួយផ្សេងនៃអង្គហេតុ ដែលច្បិចយកតែផ្នែកខ្លះ និងមិនអើពើផ្នែកពាក់ព័ន្ធជាច្រើននៃភស្តុតាង និងខកខានក្នុងការបង្ហាញថា ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងពុំមានលក្ខណៈសមហេតុផលនោះ។

### ***ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ និងប្រធាននៃគណៈប្រធានរដ្ឋ***

70. អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិ ខៀវ សំផន បានជម្រុញរបៀបវារៈបក្សកុម្មុយនីស្តកម្ពុ

ជាតាមរយៈការអានសេចក្តីថ្លែងការណ៍សារព័ត៌មាននៃសមាជជាតិពិសេសខែ មេសា ឆ្នាំ ១៩៧៥ និង សមាជជាតិលើកទីបីខែ ធ្នូ ឆ្នាំ ១៩៧៥។ ការដែលអង្គជំនុំជម្រះសាលាដំបូងពុំអាចកំណត់បញ្ហាថាតើព្រឹត្តិការណ៍នេះ បានកើតឡើងពិតប្រាកដ ដែរ ឬយ៉ាងណា ពុំជាប់ពាក់ព័ន្ធទៅនឹងការពិតដែលពុំអាចជំទាស់បានថា ការអានរបស់ ខៀវ សំផន នូវសេចក្តីថ្លែងការណ៍នេះត្រូវបានចាក់ផ្សាយតាមវិទ្យុ និងថា នេះជាការជម្រុញមាគ៌ាបក្ស។

71. អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអាចសំអាងទៅលើសកម្មភាពរបស់គាត់ជាប្រធានគណៈប្រធានរដ្ឋ ពីព្រោះតួនាទីនេះ“ត្រឹមតែជានិមិត្តរូប” ដោយសារគាត់បានយល់ច្រឡំលើសារៈសំខាន់នៃការពិពណ៌នារបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធផងដែរលើអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើទៅលើភស្តុតាងដែលថា បក្សកុម្មុយនីស្តពុំបានផ្តល់ទំនុកចិត្តលើគាត់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធផងដែរនូវអំណះអំណាងច្រំដែលរបស់គាត់ដែលថា គាត់មិនអាចរួមចំណែកក្នុងគោលបំណងរួមតាមរយៈការបំពេញកាតព្វកិច្ចការទូត និងជាទូទៅតាមរយៈការជម្រុញមាគ៌ាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងសុន្ទរកថារបស់គាត់ ពីព្រោះតាមការអះអាងរបស់គាត់ថា នេះពុំមែនជាបទល្មើសដោយខ្លួនឯងនោះទេ ឬថា គាត់ត្រឹមតែបានគាំទ្រសកម្មភាពស្លូតត្រង់ប៉ុណ្ណោះ។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញគ្រប់គ្រាន់ថា សុន្ទរកថារបស់ ខៀវ សំផន បានជម្រុញគោលនយោបាយល្មើសរបស់បក្សកុម្មុយនីស្តជាច្រើនផ្សេងៗ។

72. បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ស្របជាមួយនឹង ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានសន្និដ្ឋានពុំត្រឹមត្រូវថា សុន្ទរកថាថ្លែងនៅសម័យប្រជុំលើកទីមួយរបស់សភាតំណាងប្រជាជនជារបស់គាត់ក៏ដោយ ក៏កំហុសទាំងនេះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌ដែរ ដោយសារកំហុសនេះពុំមែនសំខាន់បំផុតដែលខ្វះមិនបាន ចំពោះការសន្និដ្ឋានពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

### *សមាជិកភាពក្នុងគណៈមជ្ឈិម*

73. ខៀវ សំផន បានទទួលស្គាល់ថា គាត់“ដំបូងគឺជាសមាជិកបម្រុង និងក្រោយមកជាសមាជិកពេញសិទ្ធិ”នៃគណៈមជ្ឈិម។ តាមទស្សនៈរបស់គាត់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារ (១) ការពន្លាតសិទ្ធិអំណាចរបស់គណៈអចិន្ត្រៃយ៍ (២) ការសន្មតសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ថា ជារបស់គណៈមជ្ឈិម (៣) “ដោយឆ្លៀតឱកាស”កំណត់កាលបរិច្ឆេទនៃការចូលរបស់គាត់ជាសមាជិកពេញ

សិទ្ធិនៃគណៈមជ្ឈិម ដើម្បីដាក់ឱ្យគាត់មានការជាប់ពាក់ព័ន្ធនៅក្នុងសេចក្ដីសម្រេចគណៈមជ្ឈិមចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ និង (៤) ការយល់ឃើញពុំត្រឹមត្រូវថា គាត់បានចូលរួមក្នុងសមាជបក្ស។

74. អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងទាំងនេះ។ សម្រាប់សំអាងហេតុពេញលេញត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់គាត់ដែលថា ពុំមែនរាល់ទូរលេខដែលបានផ្ញើទៅមជ្ឈិមបក្ស បានទៅដល់ដៃសមាជិកគណៈអចិន្ត្រៃយ៍ទាំងអស់គ្នានោះទេ ប៉ុន្តែសន្និដ្ឋានថា គាត់ត្រូវបានផ្ដល់ព័ត៌មានដោយសារជាសមាជិកនៃមន្ទីរ ៨៧០។

75. អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើសារណារបស់ ខៀវ សំផន ទាក់ទងទៅនឹងសេចក្ដីសម្រេចចំនួនបួនរបស់គណៈមជ្ឈិម៖ (១) សេចក្ដីសម្រេចក្នុងខែ ឧសភា ឆ្នាំ ១៩៧២ ឱ្យបិទផ្សារ បញ្ឈប់ការប្រើប្រាស់លុយ និងរៀបចំសហករណ៍ក្នុងតំបន់រំដោះ (២) សេចក្ដីសម្រេចនៅពាក់កណ្ដាលឆ្នាំ ១៩៧៤ ឱ្យបិទបញ្ចប់ការចូលជាសមាជិកបក្សដើម្បីរារាំងគិញមិនឱ្យជ្រៀតចូលក្នុងបក្ស (៣) សេចក្ដីសម្រេចខែ មិថុនា ឆ្នាំ ១៩៧៤ ឱ្យធ្វើការវាយសម្រុកចុងក្រោយ និងការជម្លៀសទីក្រុងភ្នំពេញក្នុងរដូវប្រាំងឆ្នាំ ១៩៧៤ ដល់ ១៩៧៥ និង (៤) 'សេចក្ដីសម្រេចថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ របស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន'។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសនៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ឬក្នុងសេចក្ដីសន្និដ្ឋានដែលថា ខៀវ សំផន បានដឹងអំពីសេចក្ដីម្រេចទាំងបីលើកដំបូងនោះដែលមានមូលដ្ឋានរឹងមាំក្នុងភស្តុតាងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈមជ្ឈិមបានតែងតាំង ខៀវ សំផន នូវតួនាទីប្រធានគណៈប្រធានរដ្ឋ។ ប្រហាក់ប្រហែលគ្នានេះដែរ អង្គជំនុំជម្រះពុំឃើញមានហេតុផលត្រូវជ្រៀតជ្រែកក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខៀវ សំផន បានរួមចំណែកក្នុងគោលបំណងរួមតាមរយៈការយល់ព្រមទៅនឹងខ្លឹមសារនៃសេចក្ដីសម្រេចនោះ។ បន្ថែមលើនេះ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានចូលរួមក្នុងសមាជបក្សលើកទីបួន និងទីប្រាំមានភស្តុតាងគ្រប់គ្រាន់គាំទ្រ។

***វត្តមាន និងការចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍***

76. អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការចូលរួមញឹកញាប់របស់ ខៀវ សំផន ក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បានផ្ដល់ឱ្យគាត់នូវតួនាទីពិសេសក្នុងបក្ស។ គាត់ត្រឹមតែលើកការបកស្រាយមួយផ្សេងអំពីភស្តុតាង និងលើកច្រំដែលនូវអំណះអំណាងនៃការជំនុំជម្រះពីសំណុំរឿង ០០២/០១ និង ០០២/០២ ដោយគ្មានការបង្ហាញថា សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងពុំសមហេតុផល។ អំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលា

ដំបូងមានកំហុសដោយសារការដាក់ឱ្យគាត់ទទួលខុសត្រូវតាមរយៈការចូលរួមក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពុំមានមូលដ្ឋានគាំទ្រឡើយ។ ផ្ទុយទៅនឹងសារណារបស់គាត់ អង្គជំនុំជម្រះសាលាដំបូងពុំបានសន្និដ្ឋានពង្រីកបញ្ចូលការចូលរួមរបស់គាត់យ៉ាងសកម្មក្នុងកិច្ចប្រជុំពីរដែលគាត់បានចូលរួមក្នុងពេលផ្សេងគ្នា ឬក្នុងការធ្វើសេចក្តីសម្រេច និងពុំបានដាក់ឱ្យគាត់ទទួលខុសត្រូវផ្អែកលើមូលដ្ឋាននេះឡើយ។

77. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គាត់បានរួមចំណែកក្នុងផែនការរួមតាមរយៈកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពិភាក្សាអំពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមក្នុងកិច្ចប្រជុំថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ប៉ុន្តែកំហុសនេះពុំបានបណ្តាលឱ្យមានភាពមិនយុត្តិធម៌នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសក្នុងការកំណត់ចរិតលក្ខណៈនៃភស្តុតាងពាក់ព័ន្ធទៅនឹងកិច្ចប្រជុំពីរដ៏ទៃទៀតដែលពិភាក្សាអំពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ អង្គជំនុំជម្រះតុលាការកំពូលរកពុំឃើញកំហុសនៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូង*ក្នុងចំណោមនោះ*ទៅលើការអះអាងរបស់ អៀង សារី ក្នុងការយល់ឃើញថា ខៀវ សំផន មានវត្តមានក្នុងកិច្ចប្រជុំខែ កញ្ញា ឆ្នាំ ១៩៧៥ ដែលពិភាក្សាអំពី"កសិកម្ម ភាពរាំងស្ងួត និងឧស្សាហ៍កម្ម"។

78. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារបានផ្អែកទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ក្នុងការយល់ឃើញថា គាត់អាចធ្វើអន្តរាគមន៍ក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងពុំបានសំអាងទៅលើគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំក្នុងការដាក់ឱ្យ ខៀវ សំផន ទទួលខុសត្រូវចំពោះសេចក្តីសម្រេចគណៈមជ្ឈិម ប៉ុន្តែលើសមាជិកភាពពេញលេញក្នុងនោះ។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសក្នុងវិធីសាស្ត្រនេះទេ។ ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំបានយល់ឃើញថា ខៀវ សំផន បានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ សារណារបស់គាត់ដែលថា គាត់អាចធ្វើអន្តរាគមន៍បាននោះចាត់ទុកជាអសារបង់។

***តួនាទីបន្ទាប់បន្សំ***

79. ខៀវ សំផន បានជំទាស់ទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើភស្តុតាងរបស់ អែម អឿន និង ឯក ហេន ក្នុងការយល់ឃើញថា គាត់បាននិយាយអំពីខ្មាំងក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនយោបាយដែលធ្វើឡើងនៅបុរីកីឡា (ក-៦) និងនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត (ក-១៥)។ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យលើភស្តុតាង និងរកពុំឃើញកំហុសក្នុងការវាយតម្លៃរបស់

អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំបានអើពើលើភស្តុតាងដទៃទៀតរបស់សាក្សីដែលចម្លើយរបស់ពួកគេបានគាំទ្រការសន្និដ្ឋានថា គាត់ជាប់ពាក់ព័ន្ធទៅនឹងវគ្គបណ្តុះបណ្តាលនយោបាយ។ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់គាត់ដែលថា ចម្លើយ"ពាក់ព័ន្ធទៅនឹងផែនការសេដ្ឋកិច្ចទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជា"អាចជាការរួមចំណែកយ៉ាងច្រើនក្នុងសហឧក្រិដ្ឋកម្មរួម។

80. អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា គាត់បានចូលរួមមន្ទីរ ៨៧០ ក្នុងខែ តុលា ឆ្នាំ ១៩៧៥។ គាត់បានលើកច្រំដែលនូវអំណះអំណាងដែលត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ និងខកខានក្នុងការបង្ហាញឱ្យជឿជាក់បានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស។ ទីពីរ អង្គជំនុំជម្រះតុលាការកំពូលបដិសេធការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានបំផ្លើសភស្តុតាងពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់ក្នុងមន្ទីរ ៨៧០។

81. ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីតួនាទីរបស់គាត់ក្នុងជំនួញ និងពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ។ ការជំទាស់ប្រហាក់ប្រហែលគ្នាជាច្រើននេះត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដោយសារគាត់ត្រឹមតែលើកការបកស្រាយមួយផ្សេងនៃភស្តុតាង។ ខៀវ សំផន បានចាត់ទុកខ្លួនគាត់ថាមានតួនាទីតូចតាចខាងបច្ចេកទេសក្នុងគណៈកម្មាធិការពាណិជ្ជកម្ម។ សារណានេះត្រូវបដិសេធចោលប្រហាក់ប្រហែលគ្នាដែរ។ អង្គជំនុំជម្រះតុលាការកំពូលពុំឃើញមានកំហុសនៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងរបស់ សគឹម ល្មុត, យ៉ុន គុជ ឬ ប៉ិត ហឿន *ហៅ* ប៉ិត ណា។

82. អង្គជំនុំជម្រះតុលាការកំពូលពុំបានចាត់ទុកថា ជាការពុំសមហេតុផលដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខៀវ សំផន បានដឹងអំពីខ្លឹមសារនៃលិខិតចំនួនពីរដែលបានផ្ញើទៅឱ្យគាត់ដោយអង្គការ*លើកលែងទោសអន្តរជាតិ* ក្នុងឆ្នាំ ១៩៧៧ និង ១៩៧៨ ដោយសារការទំនាក់ទំនងរបស់គាត់ក្នុងផ្នែកខ្លះជាមួយនឹង អៀង សារី និងក្រសួងកិច្ចការបរទេស។

## *សហឧក្រិដ្ឋកម្មរួម*

83. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តរហូតយ៉ាងហោចណាស់ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ខៀវ សំផន បានរួមចំណែកគោលបំណងរួម

ល្មើសក្នុងការអនុវត្តន៍ឆាប់រហ័សបដិវត្តសង្គមនិយមក្នុងកម្ពុជាតាមរយៈទ្រឹស្តី"មហាលោតផ្លោះមហាអស្ចារ្យ"។ យោងតាមអង្គជំនុំជម្រះសាលាដំបូងបានឱ្យដឹងថា គោលបំណងរួមគឺជាបទល្មើស ពីព្រោះមានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងគោលនយោបាយដែលជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ។ គោលនយោបាយនេះគឺជា៖ (១) ការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការ (២) ការបង្កើត និងប្រតិបត្តិមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៣) ការកំណត់គោលដៅលើក្រុមជាក់លាក់ និង (៤) បទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់បន្ថែមទៀតថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងថា គាត់បានរួមចំណែកចេតនាជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតក្នុងសហឧក្រិដ្ឋកម្មរួមតាមរយៈការចូលរួម និងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរួមបញ្ចូលតាមរយៈគោលបំណងរួម។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ខៀវ សំផន មានពិរុទ្ធដោយសារការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

84. ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើនក្នុងការកំណត់គោលបំណងរួមរបស់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យថាជាបទល្មើស។ គាត់បានជំទាស់ទៅនឹងការចាត់ទុកថា ជាបទល្មើសចំពោះគោលនយោបាយនីមួយៗរបស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានជំទាស់បន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា គាត់បានរួមចំណែកទិដ្ឋភាពល្មើសនៃគោលបំណងរួម និងថា គាត់បានរួមចំណែកសំខាន់ដល់គោលបំណងនេះ ព្រមទាំងក្នុងការយល់ឃើញថា គាត់មានចេតនាចូលរួមគោលបំណងរួម និងក្នុងបទឧក្រិដ្ឋដែលនៅពីក្រោយគោលបំណងនោះ។

85. ការចោទប្រកាន់មួយចំនួនរបស់ ខៀវ សំផន អំពីកំហុសជាប់ពាក់ព័ន្ធទៅនឹងការបញ្ជាក់របស់ អង្គជំនុំជម្រះសាលាដំបូងអំពីច្បាប់ដែលអាចអនុវត្តបានចំពោះសហឧក្រិដ្ឋកម្មរួម។ ជាឧទាហរណ៍ គាត់បានលើកឡើងក្នុងចំណោមនោះថា អំពើអសកម្មល្មើសពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវការចូលរួមក្នុងគោលបំណងរួម និងថា ទំនាក់ទំនងដែលជាលក្ខខណ្ឌតម្រូវ ត្រូវតែមានអត្ថិភាពរវាងសមាជិកសហឧក្រិដ្ឋកម្មរួម និងជាមួយចារីផ្ទាល់*ទាំងអស់* នៃឧក្រិដ្ឋកម្មមិនត្រឹមតែម្នាក់នោះទេ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងបញ្ហានេះ ដោយសារខកខានក្នុងការបង្ហាញនូវកំហុសដែលអាចប្តឹងសាទុក្ខបាន។

*លក្ខណៈល្មើសនៃគោលបំណងរួម*

86. ខៀវ សំផន បានជំទាស់ដដែលៗទៅនឹងការដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ផែនការបដិវត្តសង្គមនិយមរបស់បក្សកុម្មុយនីស្តកម្ពុជា មានលក្ខណៈល្មើស។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ដើម្បីឱ្យឈានដល់កម្រិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គោលបំណងរួមដែលជាកម្មវត្ថុនៃសកម្មភាពផែនការរវាងបុគ្គលមួយចំនួន ត្រូវតែមានចរិតលក្ខណៈល្មើស ក្នុងន័យថា អាចស្មើទៅនឹង ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ខៀវ សំផន អះអាងថា គោលបំណងនៃការអនុវត្តន៍ឆាប់រហ័សបដិវត្តសង្គមនិយមក្នុងកម្ពុជា ពុំមែនជាបទល្មើស ប៉ុន្តែផ្ទុយទៅវិញជាបញ្ហានយោបាយសុទ្ធសាធ។ ការកំណត់ចរិតលក្ខណៈបែបនេះពុំបានអើពើទាំងស្រុងលើការពិតថា ផែនការជាមូលដ្ឋានគឺត្រូវប្រើប្រាស់មធ្យោបាយចាំបាច់ដើម្បីសម្រេចបដិវត្តសង្គមនិយមក្នុងប្រទេសរួមទាំងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងទ្រង់ទ្រាយធំលើប្រជាជនកម្ពុជាក្នុងអំឡុងពេលនៃដំណើរការអនុវត្តន៍នោះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ទោះបីព្យាយាមពង្រីកការស្រមៃយ៉ាងណាក៏ពុំអាចជឿបានថា បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជាត្រូវបានអនុវត្តដោយមានក្តីមេត្តា ឬគិតគូរដល់សុខទុក្ខប្រជាជនឡើយ។ បើទោះបីជាបដិវត្តន៍សង្គមនិយមអាចមានអត្ថិភាព និងបានផ្តល់អត្ថប្រយោជន៍ដល់សង្គមដោយគ្មានការបង្ហូរឈាម ឬសកម្មភាពល្មើសក៏ដោយ ក៏នេះពុំអាចអនុវត្តចំពោះរឿងក្តីបច្ចុប្បន្ននេះឡើយ។ អាស្រ័យហេតុនេះ ការចោទប្រកាន់របស់គាត់អំពីកំហុសពាក់ព័ន្ធទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់លក្ខណៈល្មើសនៃគោលបំណងរួមត្រូវបដិសេធចោល។

87. ខៀវ សំផន បានលើកឡើងបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូងយល់ពុំត្រឹមត្រូវលើសញ្ញាណរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីសត្រូវ និងបានបង្ហាញពុំត្រឹមត្រូវនូវអត្ថិភាពនៃគោលនយោបាយលុបបំបាត់សត្រូវនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ គាត់បានអះអាងថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបានរារាំងការសន្និដ្ឋានដែលថា បទឧក្រិដ្ឋក្នុងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល និងបានអះអាងដដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភស្តុតាងក្នុងបរិបទត្រឹមត្រូវ ដូចជាបរិបទនៃការប្រទូសរ៉ាយប្រដាប់អាវុធជាមួយរបប លន់ នល់ និងក្រោយមកជាមួយប្រទេសវៀតណាម។

88. អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យឡើងវិញយ៉ាងហ្មត់ចត់លើភស្តុតាងទាក់ទងទៅនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសត្រូវពិត និងតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានសន្និដ្ឋានថា អំណះអំណាងរបស់គាត់ ពុំមានមូលដ្ឋានគាំទ្រគ្រប់គ្រាន់។ ការចោទប្រកាន់របស់គាត់អំពី

កំហុសក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយបង្កើត និងប្រតិបត្តិមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

89. ទាក់ទងទៅនឹងការបង្កើតសហករណ៍ និងការដ្ឋានធ្វើការ ខៀវ សំផន បានជំទាស់ទៅនឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលនយោបាយនេះមានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងគោលបំណងរួម និងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទប្រព្រឹត្តក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គាត់បានជំទាស់*ក្នុងចំណោមនោះ*ថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចរិតលក្ខណៈពុំត្រឹមត្រូវលើការតម្រង់ទិសផ្នែកនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងសហករណ៍ ដោយសារការមើលតែផ្នែកៗនៃឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពីជ្រុងស្តីពី“សត្រូវ”ដែលជាការដាក់បន្ទុក ប៉ុន្តែពុំបានអើពើលើភស្តុតាងដោះបន្ទុកដែលបង្ហាញក្តីបារម្ភជាដរាបចំពោះប្រជាជន។ បើទោះបីនេះពុំមានភាពចាំបាច់ក្នុងការយោងទៅលើភស្តុតាងនីមួយៗនៅក្នុងកំណត់ត្រាជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានយោងទៅលើឯកសារភាគច្រើនដែល ខៀវ សំផន បានចង្អុលបង្ហាញនោះដែរ។ ការបកស្រាយមួយបែបផ្សេងទៀតរបស់គាត់លើឯកសារទាំងនោះ ពុំគ្រប់គ្រាន់ក្នុងការបដិសេធ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្អែកលើការបកស្រាយសមហេតុផល និងត្រឹមត្រូវរបស់អង្គជំនុំជម្រះសាលាដំបូងលើឯកសារដដែលនោះឡើយ។ ការចោទប្រកាន់របស់គាត់អំពីកំហុសពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

## *គោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់ និងបទបញ្ញារៀបអាពាហ៍ពិពាហ៍*

90. ទាក់ទងទៅនឹងគោលនយោបាយកំណត់គោលដៅក្រុមជាក់លាក់ អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ខៀវ សំផន ពុំបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថាគោលនយោបាយកំណត់គោលដៅយ៉ាងទូលំទូលាយលើពុទ្ធសាសនិក ជនជាតិចាម ជនជាតិវៀតណាម ឬអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។

91. ទាក់ទងទៅនឹងគោលនយោបាយស្តីពីបទបញ្ញារៀបអាពាហ៍ពិពាហ៍ ខៀវ សំផន បានលើកឡើងថាជាការពុំអាចធ្វើទៅរួចក្នុងការបង្ហាញអត្ថិភាពនៃគោលនយោបាយល្មើសពាក់ព័ន្ធទៅនឹងការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តនៃការរំលោភសេពសន្ថវៈក្នុងបរិបទនេះ។ អង្គជំនុំជម្រះតុលាការ

កំពូលបដិសេធអំណះអំណាងនេះ។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ ការចោទប្រកាន់កំហុសរបស់គាត់ក្នុងការយល់ឃើញពាក់ព័ន្ធទៅនឹងអត្ថិភាព និងលក្ខណៈល្មើសនៃគោលនយោបាយដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបដិសេធចោល។

*ការរួមចំណែករបស់ ខៀវ សំផន*

92. បញ្ហាចាំបាច់ពីរចំណុចដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម គឺជាប់ពាក់ព័ន្ធទៅនឹងការរួមចំណែករបស់ ខៀវ សំផន និងចេតនារបស់គាត់ក្នុងការចូលរួមក្នុងគោលបំណងរួមល្មើស។ ខៀវ សំផន បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញពុំត្រឹមត្រូវថា ការគាំទ្ររបស់គាត់ ការចូលរួម និង/ឬការរួមចំណែកក្នុងទិដ្ឋភាពនៃគោលបំណងរួមដែលពុំមែនជាបទល្មើស ក្នុងការអនុវត្តបដិវត្តសង្គមនិយមក្នុងកម្ពុជាមានលក្ខណៈគ្រប់គ្រាន់បង្ហាញនូវការរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលអាចពាក់ព័ន្ធជាមួយនឹងគោលបំណងនោះ។ អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ការរួមចំណែកនេះអាចធ្វើឡើងតាមទម្រង់ជាច្រើន និងដូចបានកំណត់ពីដំបូងដោយអង្គជំនុំជម្រះតុលាការកំពូល "សូម្បីសកម្មភាពដែលតាមភិនភាគខាងក្រៅពុំជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មក៏ដោយ ក៏អាចត្រូវបានយកមកពិចារណានៅពេលកំណត់លើបញ្ហាថាតើ ជនជាប់ចោទបានរួមចំណែកសំខាន់ ដែរ ឬយ៉ាងណា"។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធអំណះអំណាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងពុំអាចពិចារណាលើសកម្មភាពដែលតាមភិនភាគខាងក្រៅបានកំណត់គោលដៅលើការអនុវត្តបដិវត្តសង្គមនិយមដែលខុសពីការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ នៅពេលកំណត់ថា គាត់បានរួមចំណែកយ៉ាងសំខាន់ដល់ការជម្រុញគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួមនោះ។

93. ប្រហាក់ប្រហែលគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបដិសេធសារណារបស់ ខៀវ សំផន ដែលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងជាចាំបាច់បានដាក់ឱ្យគាត់"ទទួលខុសត្រូវជារួម" ឬពិរុទ្ធភាពរបស់សមាគម ពីព្រោះតាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងឃើញថា អង្គជំនុំជម្រះច្បាស់ណាស់បានផ្អែកការសន្និដ្ឋានរបស់ខ្លួនអំពីការរួមចំណែកសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមទៅលើសកម្មភាព ឬអំពើផ្ទាល់ខ្លួនរបស់គាត់ ដែលខុសគ្នាពីអំពើរបស់អ្នកដទៃ។ ការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសពាក់ព័ន្ធទៅនឹងការរួមចំណែកសំខាន់របស់គាត់ក្នុងគោលបំណងរួមល្មើសនៃសហឧក្រិដ្ឋកម្មរួម ត្រូវបដិសេធចោល។

*ការដឹង និងចេតនារបស់ ខៀវ សំផន*

94. ទាក់ទងទៅនឹងបញ្ហាថាតើ គាត់បានដឹង និងមានចេតនាចង់ឱ្យការប្រព្រឹត្តឧក្រិដ្ឋកម្មជាមូលដ្ឋានកើតឡើងតាមរយៈគោលបំណងរួម ដែរ ឬយ៉ាងណា ខៀវ សំផន បានជំទាស់ទៅនឹងការយល់ឃើញនេះ និងបានបន្ថែមថា គោលបំណងរួមនេះពុំមែនជាបទល្មើស។ ខៀវ សំផន ពុំបានបដិសេធថា គាត់ និងសមាជិកដទៃទៀតនៃក្រុមនោះបានរួមចំណែកចេតនារួមក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមធ្វើកសិកម្មគ្មានការបែងចែកវណ្ណៈ ខ្លួនទីពឹងខ្លួន តាមរយៈបដិវត្តសង្គមនិយម ប៉ុន្តែគាត់នៅតែទទូចថា ពួកគេពុំដែលមានបំណងប្រព្រឹត្តបទឧក្រិដ្ឋជាលក្ខណៈបុគ្គល ឬជាក្រុម និងថា គោលបំណងរួមរបស់ពួកគេមានលក្ខណៈស្លូតត្រង់ និងដើម្បីអត្ថប្រយោជន៍ប្រជាជនកម្ពុជាទាំងមូល។ ខៀវ សំផន បានអះអាងថា បទឧក្រិដ្ឋណាមួយដែលអាចកើតឡើងក្នុងដំណើរការនៃការអនុវត្តន៍គោលបំណងរួម ពុំជាប់ពាក់ព័ន្ធ និងបានកើតឡើងដោយគាត់ពុំបានដឹង ឬបានចូលរួម។

95. តាមការពិនិត្យលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងឃើញថា អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យពេញលេញ និងបានអនុវត្តលក្ខខណ្ឌតម្រូវអត្តនោម័តិនៃសហឧក្រិដ្ឋកម្មរួមសម្រាប់បទឧក្រិដ្ឋនីមួយៗដែលបានចោទប្រកាន់នោះ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យបញ្ហានេះទាក់ទងទៅនឹងការដឹងរបស់ ខៀវ សំផន ដែលត្រូវបានដាក់ឱ្យទទួលខុសត្រូវក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ និងអ្នកចូលរួមយ៉ាងសកម្មនៅក្នុងស្ថាប័នដែលជាបេះដូងនៃបក្សកុម្មុយនីស្តកម្ពុជា និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំកំពូលៗនោះ។ ដោយផ្ទុយពីការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងបានដាក់"ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមរយៈអំពើរបស់អ្នកដទៃ"មកលើគាត់ដោយពុំត្រឹមត្រូវ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានចេតនារបស់គាត់ចេញពីសកម្មភាព និងអំពើផ្ទាល់របស់គាត់។

96. អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ក្នុងការសន្និដ្ឋានថា ខៀវ សំផន មានធាតុផ្សំអត្តនោម័តិតម្រូវក្រោមសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះសាលាដំបូងបានពិចារណាច្បាស់លាស់ថា គាត់បានដឹងដោយផ្ទាល់នៅពេលនោះអំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម និងបានរួមចំណែកចេតនាក្នុងការប្រព្រឹត្តជាមួយនឹងសមាជិកសហឧក្រិដ្ឋកម្មរួមដទៃទៀត។

97. កំហុសមួយចំនួនដែល ខៀវ សំផន ចោទប្រកាន់ពាក់ព័ន្ធទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការដឹងរបស់គាត់នៅពេលនោះ និងចេតនារួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មតាមសហករណ៍ និងការដ្ឋានធ្វើការ មន្ទីរសន្តិសុខ និងលើក្រុមជាក់លាក់ ដូចជា ជនជាតិចាម ពុទ្ធសាសនិក និងជនជាតិវៀតណាម

ម និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបដិសេធចោល។ សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកាជាលាយលក្ខណ៍អក្សរ។

98. អង្គជំនុំជម្រះតុលាការកំពូលបដិសេធប្រហាក់ប្រហែលគ្នានេះដែរនូវការអះអាងរបស់ ខៀវ សំផន ដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា គាត់បានដឹង និងមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងការដាក់បទបញ្ជារៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយក្នុងសាលដីកាពេញលេញជាលាយលក្ខណ៍អក្សរនូវអំណះអំណាង របស់ ខៀវ សំផន ដែលគាំទ្រការលើកឡើងទាំងនេះ ដែលភាគច្រើននៃអំណះអំណាងនេះ ត្រឹមតែជាការបកស្រាយមួយបែបផ្សេងលើភស្តុតាង។ អំណះអំណាងរបស់ ខៀវ សំផន អំពីកំហុសនោះ ត្រូវបដិសេធចោល។

*ភាពអាចអនុវត្តបាននៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយចេតនាប្រយោល*

99. ដោយសារជាបញ្ហាចុងក្រោយពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូលបានកំណត់*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសក្នុងការបញ្ជាក់ និងអនុវត្តច្បាប់ទាក់ទងទៅនឹងការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមសម្រាប់បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយចេតនាប្រយោល។ បើទោះបីជាពុំមានភាគីណាមួយបានលើកបញ្ហានេះនៅបណ្តឹងសាទុក្ខក៏ដោយ ក៏ទោះជាយ៉ាងណាក្តីអង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការចាំបាច់ក្នុងការដោះស្រាយបញ្ហានេះដោយសារមានសារៈសំខាន់ទូទៅសម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក.ដែរ។

100. អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "លក្ខខណ្ឌតម្រូវនៃកម្រិតចេតនាក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ I គឺចេតនាផ្ទាល់" និងថា "ចេតនាប្រយោល(*dolus eventualis*) ពុំគ្រប់គ្រាន់សម្រាប់ការយល់ឃើញអំពីសហឧក្រិដ្ឋកម្មរួមចំពោះមុខ អ.វ.ត.ក. នោះទេ"។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា បទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ពុំស្ថិតក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងអាស្រ័យហេតុនេះបានធ្វើការវិភាគលើការទទួលខុសត្រូវរបស់ ខៀវ សំផន ចំពោះបទឧក្រិដ្ឋនេះក្រោមទម្រង់នៃការទទួលខុសត្រូវនៃការជួយទំនុកបម្រុងជំនួសវិញ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសារពុំបានអើពើលើការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ដែលថាជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋដែលពុំមែនជាចេតនាផ្ទាល់ ប៉ុន្តែត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។

101. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលរំឭកការយល់ឃើញរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ ថា ការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមសម្រាប់បទឧក្រិដ្ឋដែលពុំស្ថិតក្នុងគោលបំណងរួម (ដូចជា សហឧក្រិដ្ឋកម្មរួមទម្រង់ III) ពុំមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និងថា ការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មរួមចំពោះមុខ អ.វ.ត.ក. អាចត្រឹមតែមានអត្ថិភាពសម្រាប់បទឧក្រិដ្ឋដែលស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា ត្រឹមតែការដឹងជាមុនថាមានការប្រព្រឹត្តបទឧក្រិដ្ឋ បទឧក្រិដ្ឋនោះជាស្វ័យប្រវត្តិពុំស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមឡើយ។ នេះជាការពុំអើពើទៅលើស្ថានការណ៍ដែលការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ ត្រូវបានយល់ព្រមជារួម និងដោយចេតនាពីសំណាក់អ្នកចូលរួមនៃសហឧក្រិដ្ឋកម្មរួមទាំងអស់។ ក្នុងស្ថានភាពនេះ ដោយសារអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមទាំងអស់បានរួមចំណែកការឯកភាពរបស់ខ្លួនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដោយចេតនាប្រយោលក្នុងការជម្រុញគោលបំណងរួម ឧក្រិដ្ឋកម្មនោះត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនោះ។

102. កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងបាននាំទៅរកការកំណត់ថា អំពើមនុស្សឃាតដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោលនៅតាមទីតាំងខាងក្រោមនោះ ពុំស្ថិតក្នុងវិសាលភាពនៃគោលបំណងរួមដូចជា៖ សហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់១មករា ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ខៀវ សំផន មានពិរុទ្ធដោយសារការជួយទំនុកបម្រុងអំពើមនុស្សឃាតទាំងនោះដោយចេតនាប្រយោល។

103. សម្រាប់សំអាងហេតុពេញលេញ ត្រូវបានពន្យល់ក្នុងសាលដីកានេះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនៅតាមទីតាំងទាំងនេះ ត្រូវបានរួមបញ្ចូលតាមរយៈគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម និងថា ខៀវ សំផន បានរួមចំណែកយ៉ាងសំខាន់ដល់គោលបំណងនោះដោយបានរួមចំណែកចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនេះខណៈពេលបានដឹងអំពីភាវនីយភាពខ្ពស់នៃការស្លាប់នោះ។ មន្ទីរសន្តិសុខភ្នំក្រោល ត្រូវបានដកចេញពីការវិភាគនេះ ពីព្រោះដូចបានពិភាក្សាខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ត្រូវបានបង្ហាញពាក់ព័ន្ធទៅនឹងទីតាំងនោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលធ្វើការកែប្រែទម្រង់នៃការទទួលខុសត្រូវពីការជួយទំនុកបម្រុងទៅជាសហឧក្រិដ្ឋកម្មរួម សម្រាប់បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់១មករា

ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពុំធ្វើការពិចារណាលើការលើកឡើងដទៃទៀតរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងការជួយទំនុកបម្រុងឡើយ។

## ការដាក់ទោស

104. អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ខៀវ សំផន បច្ចុប្បន្នកំពុងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតដែលជាទោសអតិបរមានៅចំពោះមុខ អ.វ.ត.ក. ដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ និងត្រូវបានតម្កល់នៅដំណាក់កាលបណ្តឹងសាទុក្ខ។ ដោយសារសំណុំរឿង ០០២/០១ និង ០០២/០២ ដែលត្រូវបានចោទប្រកាន់ដាច់ដោយឡែកពីគ្នា ប៉ុន្តែកើតចេញពីដីកាបញ្ជូនទៅជំនុំជម្រះតែមួយដែលត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីដើម្បីអត្ថប្រយោជន៍ងាយស្រួលចាត់ចែងការជំនុំជម្រះ និងដោយផ្អែកលើបញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទទាំងអស់។ បើទោះបីជាមានទំនាក់ទំនងគ្នាក៏ដោយ ក៏រឿងក្តីនេះដោះស្រាយលើអង្គហេតុផ្សេងគ្នាដែលត្រូវបានវិនិច្ឆ័យក្នុងការជំនុំជម្រះចំនួនពីរដែលបង្កើតឱ្យមានផ្នែកសម្រេចសេចក្តីដាច់ដោយឡែកពីគ្នា ដែលនីមួយៗតម្រូវឱ្យមានការដាក់ទោសផ្សេងៗគ្នាបន្ទាប់ពីរកឃើញពិរុទ្ធភាព។ សម្រាប់ហេតុផលនេះ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិតសម្រាប់បទឧក្រិដ្ឋដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពក្នុងសំណុំរឿង ០០២/០២ ហើយអង្គជំនុំជម្រះតុលាការកំពូលតម្កល់ការដាក់ទោសនេះ។ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកការដាក់ទោសអស់មួយជីវិតដែលបានធ្វើឡើងក្នុងសំណុំរឿង ០០២/០២ ជាការសមស្រប ដោយផ្អែកលើកាលៈទេសៈទាំងអស់ រួមទាំងព្រឹត្តិការណ៍ដ៏មហាសោកនាដកម្ម និងវិសាលភាពនៃព្យសនកម្មដែលបានបង្កដោយ ខៀវ សំផន។ ទោះជាយ៉ាងណាក្តី ក្នុងកាលៈទេសៈនេះ ដោយបន្ថែមទៅលើការតម្កល់ទោសជាប់ពន្ធនាគារអស់មួយជីវិតក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតក្នុងរឿងក្តីបច្ចុប្បន្ន ត្រួតគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតដែលបានប្រកាសក្នុងសំណុំរឿង ០០២/០១ ស្របតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា។

105. ទោះជាយ៉ាងណាក្តី ខៀវ សំផន បានលើកការជំទាស់ជាច្រើនទៅនឹងភាពត្រឹមត្រូវនៃការដាក់ទោសដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២។ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការពិពណ៌នាគោលបំណងបឋមនៃការដាក់ទោស និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋតាមរយៈការដាក់បញ្ចូលក្នុងការវិភាគរបស់

ខ្លួននូវបទឧក្រិដ្ឋដែលគាត់ពុំត្រូវបានចោទប្រកាន់ និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើកត្តាទម្ងន់ទោស រួមទាំងការគិតបញ្ចូលពីរដងនូវតួនាទីរបស់គាត់នៃសិទ្ធិអំណាច និងឥទ្ធិពលថា ជាកត្តាទម្ងន់ទោសទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងចុងក្រោយថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើកត្តាសម្រាលទោស។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាដោយហ្មត់ចត់នូវការអះអាងនីមួយៗទាំងនោះ និងចាត់ទុកថា គ្មានមូលដ្ឋានគាំទ្រ។ករណីលើកលែងតែមួយគឺការអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើង ដោយបានរួមបញ្ចូលបទឧក្រិដ្ឋដែល ខៀវ សំផន ពុំត្រូវបានចោទប្រកាន់ និងការគិតបញ្ចូលពីរដងនៃតួនាទីរបស់ ខៀវ សំផន នៃសិទ្ធិអំណាច និងឥទ្ធិពល។ បើទោះបីជាអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការធ្វើដូច្នោះគឺជាកំហុសក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា ក្នុងកាលៈទេសៈនៃរឿងក្តីនេះ ការពិចារណានោះពុំបានបណ្តាលឱ្យការប្រកាសទោសចុងក្រោយទៅជាពុំសមស្រប ឬមិនយុត្តិធម៌ណាមួយឡើយ។

## **ផ្នែកសម្រេចសេចក្ដី៖**

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖**

**ដោយអនុលោមមាត្រា** ៤(១)(ខ) នៃកិច្ចព្រមព្រៀង អ.វ.ត.ក. មាត្រា ១៤ ថ្មី (១)(ខ) និង ៣៦ ថ្មីនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. និងវិធាន ១១១ នៃវិធានផ្ទៃក្នុង ។

**កត់សម្គាល់លើ**សារណាជាលាយលក្ខណ៍អក្សរនីមួយៗរបស់ភាគីលើបណ្ដឹងសាទុក្ខ និងអំណះអំណាងដែលបានបង្ហាញនៅពេលសវនាការថ្ងៃទី ១៦ ដល់ ១៩ ខែ សីហា ឆ្នាំ ២០២១ ។

**ទទួលយក** ផ្នែកខ្លះ និង**បដិសេធ** ផ្នែកខ្លះនៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន **ដែលក្នុងនោះ៖**

- **ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការស្លាប់ដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់៖**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទជួយទំនុកបម្រុង នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល និង **កែប្រែ**ប្រភេទគតិយុត្តិនៃបទល្មើស ដោយសម្រេច **ដាក់ពិរុទ្ធភាព** លើ **ខៀវ សំផន** ពីបទមនុស្សឃាតដោយចេតនាប្រយោល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួមវិញ ។

- **ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការស្លាប់ដែលបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល៖**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទមនុស្សឃាត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- **ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើទុក្ខបុកម្នេញនៅការដ្ឋានធ្វើការទំនប់ ១មករា៖**

  **បដិសេធ** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រជាជនថ្មី ។

- **<u>ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ជនជាតិចាមដែលបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការសម្លាប់រង្គាល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើការដោយបង្ខំរបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខត្នុំក្រោល ÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការដាក់ឱ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការនិរទេសប្រជាជនវៀតណាមចេញពីស្រុកត្រាំកក់ និងពីខេត្តព្រៃវែង÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការនិរទេសជនជាតិវៀតណាម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការធ្វើបាបផ្លូវចិត្ត និងផ្លូវកាយលើជនជាតិចាមនៅភូមិទ្រា÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទារុណកម្ម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការប្រព្រឹត្តនៅលើជនជាតិចាម និងការចាត់ទុកជា"សត្រូវពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា" រួមទាំងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និង "ប្រជាជនថ្មី"នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា (មិនជាប់ពាក់នៅនឹង"ប្រជាជនថ្មី") ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខត្នុំក្រោល÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការរើសអើងលើជនជាតិចាម÷</u>**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

- **ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការរើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃនៃពុទ្ធសាសនាៈ**
  - **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។
- **ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការរើសអើងជនជាតិវៀតណាមនៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង និងខេត្តព្រៃវែង និងស្វាយរៀងៈ**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។
- **ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោលៈ**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** ដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។
- **ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការផ្លាស់ទីដោយបង្ខំជនជាតិចាមក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅ ប្រជាជន ដំណាក់កាលទីពីរៈ**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** ដែលត្រូវបានចាត់ទុកថា ជាការផ្លាស់ទីដោយបង្ខំ ។
- **ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៃគោលនយោបាយបទបញ្ជារៀបអាពាហ៍ពិពាហ៍ទូទាំងប្រទេសៈ**

  **តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងបន្ថែមលើសពីនេះ ពី **បទ** អំពើអមនុស្សធម៌ដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹង **ជនរងគ្រោះជាស្ត្រី**។

  **ទទួលយក** ផ្នែកខ្លះ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងសម្រេច **ដាក់ពិរុទ្ធភាព** លើ **ខៀវ សំផន** ពីបទអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ **អំពើ** នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមលើសនេះ ពីបទ អំពើអមនុស្សធម៌ដទៃទៀតក្នុង

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹង **ជនរងគ្រោះជាបុរស** ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបន្តឱ្យមានការឈឺចាប់ ឬរបួសធ្ងន់ធ្ងរលើរូបកាយ ឬសុខភាព ការដកហូតឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិលៈ</u>**

**តម្កល់**ការដាក់ពិរុទ្ធភាព ខៀវ សំផន ពីបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។

- **<u>ពាក់ព័ន្ធនៅនឹងអង្គហេតុនៃការសម្លាប់ជនជាតិវៀតណាមៈ</u>**

**តម្កល់** ការដាក់ពិរុទ្ធភាពលើ **ខៀវ សំផន** ពីបទប្រល័យពូជសាសន៍ ។

- **ប្រកាសតម្កល់** ការប្រកាសទោស **ដាក់ពន្ធនាគារអស់មួយជីវិត លើ ខៀវ សំផន** របស់អង្គជំនុំជម្រះសាលាដំបូង ។
- **ប្រកាសថា** ទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងសំណុំរឿង ០០២/០២ នេះ ត្រូវអនុវត្តត្រួតគ្នាជាមួយនឹងទោសដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង ០០២/០១។

**បង្គាប់ថា ខៀវ សំផន** ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការចេញសាលដីកាមានសំអាងហេតុពេញលេញ និងការបញ្ចប់នូវការរៀបចំសម្រាប់ការផ្ទេរដោយអនុលោមតាមច្បាប់ទៅពន្ធនាគារដែលគាត់ត្រូវបន្តអនុវត្តទោសរបស់គាត់ ។